ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៩៣ ត្រីមាសទី០៤ ឆ្នាំ២០២០

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៤-១១-២០២០ -ព្រះរាជក្រម នស/រកម/១១២០/០២៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាង ព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ១១៤៣៣

២~ព្រះរាជក្រឹត្យ

១១-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ចំនួន ១០ រូប ១១៤៦៩

១១-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៥៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម ចំនួន ២ រូប ១១៤៧០

១១-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៥៨ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **ស៊ុន សារី** និងតាំងស៊ប់ក្នុងក្របខ័ណ្ឌ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់មន្ត្រីរាជការ ២២២ រូប ១១៤៧១

១១-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៥៩ ស្តីពី ការផ្តល់គោរមងារលោក **ឡាយ ម៉ុនរិទ្ធ** ជា ឧកញ៉ា ១១៤៨០

១១-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦០ ស្តីពី ការផ្តល់គោរមងារលោក **ម៉ម វណ្ណឌី** ជា ឧកញ៉ា ១១៤៨១

១២-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អស់លោក ចំនួន ២ រូប ១១៤៨២

១២-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦២ ស្តីពី ការផ្តល់គោរមងារលោក **ឈិន ម៉េង** ជា ឧកញ៉ា ១១៤៨៣

១២-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៣ ស្តីពី ការផ្តល់គោរមងារលោក **ឃិន ម៉ាន់** ជា ឧកញ៉ា ១១៤៨៤

១២-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៤ ស្តីពី ការផ្តល់គោរមងារលោក **ខូយ អ៊ិងឡាយ** ជា ឧកញ៉ា ១១៤៨៥

១២-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក ឧបាសិកា និងព្រះសង្ឃ ចំនួន ៤៣ រូប/អង្គ ១១៤៨៦

១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **ហ័ង ផៃឈុន** (WANG, PEICHUN) ជនជាតិចិន សញ្ជាតិចិន	១១៤៨៨
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី ហ្វូតឺ** (LI FUDE) ជនជាតិចិន សញ្ជាតិចិន	១១៤៨៩
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ស៊ី ជិនហាយ** (XU, ZHENHAI) ជនជាតិចិន សញ្ជាតិចិន	១១៤៩០
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៦៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី មីងឈឹង** (LI, MINGCHENG) ជនជាតិចិន សញ្ជាតិចិន	១១៤៩១
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ប៉ោជីង** (CHEN, BAOJING) ជនជាតិចិន សញ្ជាតិចិន	១១៤៩២
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ហ្គួហ្វេង** (WANG GUOFENG) ជនជាតិចិន សញ្ជាតិចិន	១១៤៩៣
១២-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ហ័ង ផេងហ្វី** (HUANG PENGFEI) ជនជាតិចិន សញ្ជាតិចិន	១១៤៩៤
១៥-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧៣ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **សុខ សទ្ធារ** ជាអនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍	១១៤៩៥
១៦-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧៤ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **សុខ សុភាន** ជារដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	១១៤៩៦
១៦-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧៥ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **អ៊ឹង រី** ពីទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក	១១៤៩៧
១៦-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១០ រូប	១១៤៩៨
១៦-១២-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១២២០/១៣៧៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ អស់លោក ចំនួន ៣ រូប	១១៥០០

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

១-១២-២០២០	-អនុក្រឹត្យលេខ ១៩៨ អនក្រ.បក ស្តីពី យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន	១១៥០១
២-១២-២០២០	-អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ	១១៥១២

២៤-១១-២០២០	-អនុក្រឹត្យលេខ ១០១៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ	១១៥១៥
២៦-១១-២០២០	-អនុក្រឹត្យលេខ ១០១៦ អនក្រ.តត ស្ដីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ	១១៥១៩
២៦-១១-២០២០	-អនុក្រឹត្យលេខ ១០១៧ អនក្រ.តត ស្ដីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា	១១៥២០
២៦-១១-២០២០	-អនុក្រឹត្យលេខ ១០១៨ អនក្រ.តត ស្ដីពី ការតែងតាំងផ្លាស់ប្ដូរមុខតំណែង នាយទាហាន	១១៥២១
២៦-១១-២០២០	-អនុក្រឹត្យលេខ ១០១៩ អនក្រ.តត ស្ដីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ	១១៥២៣
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២០ អនក្រ.តត ស្ដីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា	១១៥២៤
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២១ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ	១១៥២៥
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ	១១៥២៦
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៣ អនក្រ.តត ស្ដីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ	១១៥២៨
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៤ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ	១១៥៣០
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៥ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	១១៥៣២
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៦ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	១១៥៣៥
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៧ អនក្រ.តត ស្ដីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ	១១៥៣៨
៣០-១១-២០២០	-អនុក្រឹត្យលេខ ១០២៨ អនក្រ.តត ស្ដីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន	១១៥៤២
១-១២-២០២០	-អនុក្រឹត្យលេខ ១០២៩ អនក្រ.តត ស្ដីពី ការដំឡើងឋានៈមន្ត្រីការទូតជាន់ខ្ពស់ប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស	១១៥៤៣
២-១២-២០២០	-អនុក្រឹត្យលេខ ១០៣០ អនក្រ.តត ស្ដីពី ការនិយ័តកម្មក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដល់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ	១១៥៤៥
២-១២-២០២០	-អនុក្រឹត្យលេខ ១០៣១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ	១១៥៤៧
៣-១២-២០២០	-អនុក្រឹត្យលេខ ១០៣២ អនក្រ.តត ស្ដីពី ការតែងតាំងជំនួយការក្រសួងមហាផ្ទៃ	១១៥៤៨
៣-១២-២០២០	-អនុក្រឹត្យលេខ ១០៣៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ	១១៥៤៩
៧-១២-២០២០	-អនុក្រឹត្យលេខ ១០៣៤ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ	១១៥៥១

III~ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-២-២០២០	-ប្រកាសលេខ ១៩១ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	១១៥៥២

ព្រះរាជក្រម

នស/រកម/១១២០/០២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

មាត្រា១.-

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ។

ថ្ងៃ សៅរ៍ ១៤កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២០

នស/រកម/១១២០/០២៧

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កើត រិទ្ធ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

សន្ធិសញ្ញា

ស្តីពី

ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

រវាង

ព្រះរាជាណាចក្រកម្ពុជា

និង

សហព័ន្ធរុស្ស៊ី

សន្ធិសញ្ញា
ស្តីពី
ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
រវាង
ព្រះរាជាណាចក្រកម្ពុជា
និង
សហព័ន្ធរុស្ស៊ី

ព្រះរាជាណាចក្រកម្ពុជា និង សហព័ន្ធរុស្ស៊ី ចាប់ពីពេលនេះតទៅហៅកាត់ថា "គូភាគី"៖

ដោយទទួលស្គាល់ទំនាក់ទំនងជាមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងគូភាគី

ដោយមានគោលបំណងពង្រឹងមូលដ្ឋានច្បាប់នៃការផ្តល់ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ

ដោយមានគោលបំណងធ្វើឲ្យកាន់តែប្រសើរនូវប្រសិទ្ធភាពនៃសកម្មភាពរបស់ភាគីទាំងពីរក្នុងការប្រឆាំងបទល្មើសដោយរាប់បញ្ចូលទាំងបទល្មើសទាក់ទងនឹងភេរវកម្ម តាមរយៈកិច្ចសហប្រតិបត្តិការនិងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

ដោយអនុលោមតាមច្បាប់របស់គូភាគីនិងគោរពគោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ជាទូទៅជាពិសេស គឺគោលការណ៍នៃសមភាព អធិបតេយ្យភាព សុចរិតភាពដែនដី និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក

បានព្រមព្រៀងគ្នាដូចតទៅ៖

មាត្រា១
វិសាលភាពនៃជំនួយផ្នែកច្បាប់

ជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (តទៅនេះហៅថា"ជំនួយផ្នែកច្បាប់") រួមមាន៖

១-សេវាកម្មឯកសារ

២-ការទទួលបាននូវភស្តុតាងនិងចម្លើយរបស់បុគ្គល

៣-ទីតាំងនិងអត្តសញ្ញាណរបស់បុគ្គល

៤-ទីតាំងនិងអត្តសញ្ញាណរបស់វត្ថុព្រមទាំងផលនៃបទល្មើសនិងមធ្យោបាយប្រព្រឹត្តបទល្មើសរាប់បញ្ចូលទាំងមធ្យោបាយសម្រាប់ប្រព្រឹត្តអំពើភេរវកម្មផងដែរ

៥-ការជូនដំណឹងទៅសាក្សី ជនរងគ្រោះ និងអ្នកជំនាញ អំពីសំណើឲ្យមកបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីធ្វើសំណើ

៦-ការផ្ទេរជាបណ្តោះអាសន្នចំពោះបុគ្គលដែលកំពុងជាប់ឃុំឬជាប់ពន្ធនាគារ ដើម្បីផ្តល់សក្ខីកម្មឬជួយដល់ការស៊ើបអង្កេត ក្រោមសន្ធិសញ្ញានេះ

៧-ការអនុវត្តវិធានការទាក់ទងនឹងទ្រព្យសម្បត្តិ

៨-ការផ្ទេរឯកសារ វត្ថុ និងភស្តុតាងដទៃទៀត

៩-ការផ្តល់ការអនុញ្ញាតដល់តំណាងអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីធ្វើសំណើដើម្បីឱ្យមានវត្តមាននៅពេលអនុវត្តសំណើ

១០-ការឆែកឆេរនិងដកហូត

១១-ការផ្តល់ជំនួយផ្នែកច្បាប់ដទៃទៀតដែលស្របនឹងសន្ធិសញ្ញានេះដរាបណាទង្វើបែបនេះមិនផ្ទុយទៅនឹងច្បាប់របស់ភាគីទទួលសំណើ។

មាត្រា២
ភាពព្វកិច្ចក្នុងការផ្តល់ជំនួយផ្នែកច្បាប់

១-យោងតាមសន្ធិសញ្ញានេះ គូភាគីត្រូវផ្តល់ឲ្យគ្នាទៅវិញទៅមកនូវជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយក្នុងករណីព្រហ្មទណ្ឌ

២-យោងតាមសន្ធិសញ្ញានេះ ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់ជូនប្រសិនបើបទល្មើសដែលជាកម្មវត្ថុនៃសំណើ គឺជាបទល្មើសព្រហ្មទណ្ឌដែលអាចផ្តន្ទាទោសបានក្រោមច្បាប់នៃភាគីទាំងសងខាង។ ក្រោយពេលពិចារណា ភាគីទទួលសំណើអាចផ្តល់ជំនួយផ្នែកច្បាប់បានផងដែរ ក្នុងករណីបទល្មើសជាកម្មវត្ថុនៃសំណើដែលបានទទួលនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌដែលអាចផ្តន្ទាទោសបានក្រោមបទបញ្ញត្តិរបស់ខ្លួន។

៣-សន្ធិសញ្ញានេះមានគោលបំណងផ្តល់ជំនួយផ្នែកច្បាប់ដោយភាគីមួយទៅភាគីមួយទៀត តែម្យ៉ាងគត់។ បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះមិននាំឲ្យមានការបង្កើតនូវសិទ្ធសម្រាប់រូបវន្តបុគ្គលឬនីតិបុគ្គលក្នុងការទទួលបានឬដកចេញនូវភស្តុតាងឬបង្អាក់ការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ឡើយ។

៤-គោលបំណងជំនួយផ្នែកច្បាប់នៃសន្ធិសញ្ញានេះ សំដៅចំពោះរាល់ជំនួយទាំងឡាយណាដែលភាគីទទួលសំណើបានផ្តល់ជូនទាក់ទង នឹងការស៊ើបអង្កេតនិងដំណើរការនីតិវិធីនៅក្នុងយុត្តាធិការរបស់ភាគីផ្ញើសំណើក្នុងករណីព្រហ្មទណ្ឌ ដោយមិនប្រកាន់ថា ជំនួយនោះកំពុងត្រូវបានគេធ្វើការស្វែងរកឬនឹងត្រូវផ្តល់ជូនដោយតុលាការឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត។

៥-ជំនួយផ្នែកច្បាប់ក៏ត្រូវផ្តល់ជូនផងដែរ សម្រាប់ការស៊ើបអង្កេតឬដំណើរការនីតិវិធីទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ដូចជា ពន្ធដារ គយ និងអាករដែលមានលក្ខណៈស្រដៀងគ្នា ការផ្ទេរទ្រព្យសម្បត្តិហិរញ្ញវត្ថុលក្ខណៈអន្តរជាតិ ដោយរាប់បញ្ចូលទ្រព្យសម្បត្តិទាំងឡាយណាដែលភាគីផ្ញើសំណើ យល់ឃើញថាអាចយកទៅប្រើប្រាស់ដើម្បីធ្វើសកម្មភាពឧក្រិដ្ឋកម្មមានការចាត់តាំងនិងឧក្រិដ្ឋកម្មដែលអាចត្រូវផ្តន្ទាទោសស្របតាមសន្ធិសញ្ញាអន្តរជាតិពហុភាគីដែលភាគីទាំងពីរជាភាគីចូលរួមនៅក្នុងវិស័យនៃការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។

៦-សន្ធិសញ្ញានេះពុំផ្តល់ឲ្យអាជ្ញាធរមានសមត្ថកិច្ចនៃភាគីមួយនូវសិទ្ធិក្នុងការអនុវត្តអំណាចនៅក្នុងទឹកដីរបស់ភាគីម្ខាងទៀតឡើយ អាស្រ័យដោយអំណាចទាំងនោះស្ថិតក្រោមសមត្ថកិច្ចរបស់ភាគីម្ខាងទៀតតែប៉ុណ្ណោះ។

៧-សន្ធិសញ្ញានេះត្រូវអនុវត្តចំពោះសំណើសុំជំនួយផ្នែកច្បាប់ដែលត្រូវផ្តល់ជូនបន្ទាប់ពីសន្ធិសញ្ញានេះបានចូលជាធរមាន បើទោះបីជាបទល្មើសពាក់ព័ន្ធឬការខកខានបំពេញករណីយកិច្ច បានកើតឡើងមុនកាលបរិច្ឆេទចូលជាធរមាននៃសន្ធិសញ្ញានេះក៏ដោយ។

មាត្រា៣
អាជ្ញាធរកណ្តាល

១-ដើម្បីផ្តល់អំពីកិច្ចសហប្រតិបត្តិការសមស្របរបស់គូភាគីនៅក្នុងក្របខណ្ឌនៃសន្ធិសញ្ញានេះ ត្រូវមានការតែងតាំងអាជ្ញាធរកណ្តាលមួយសម្រាប់ភាគីនីមួយៗ។

សម្រាប់ព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរកណ្តាលគឺ ក្រសួងយុត្តិធម៌

សម្រាប់សហព័ន្ធរុស្ស៊ី អាជ្ញាធរកណ្តាលគឺ៖

- ក្រសួងយុត្តិធម៌នៃសហព័ន្ធរុស្ស៊ី សម្រាប់គោលបំណងទាក់ទងនឹងដំណើរការនីតិវិធីរបស់តុលាការនៃសហព័ន្ធរុស្ស៊ី
- ការិយាល័យអគ្គរដ្ឋអាជ្ញា សម្រាប់រាល់គោលបំណងដទៃទៀតនៃការផ្តល់ជំនួយផ្នែកច្បាប់។

គូភាគីត្រូវជូនដំណឹងគ្នាទៅវិញទៅមកភ្លាម តាមរយៈបណ្តាញការទូតអំពីរាល់ការប្រែប្រួលនៃអាជ្ញាធរកណ្តាលរបស់ខ្លួននិងវង្វង់ដែនសមត្ថកិច្ចរបស់ពួកគេ។

២-អាជ្ញាធរកណ្តាលនៃគូភាគីត្រូវបញ្ជូននិងទទួលដោយផ្ទាល់ចំពោះរាល់សំណើសុំជំនួយផ្នែកច្បាប់ដែលមានចែងនៅក្នុងសន្ធិសញ្ញានេះនិងឆ្លើយតបចំពោះសំណើទាំងនោះ។

៣-អាជ្ញាធរកណ្តាលត្រូវអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ដោយផ្ទាល់ឬក្នុងករណីចាំបាច់ត្រូវបាត់ចែងឲ្យអាជ្ញាធរមានសមត្ថកិច្ចណាមួយអនុវត្ត និងធ្វើការសម្របសម្រួលយ៉ាងឆាប់រហ័ស និងសមស្របដើម្បីអនុវត្តសំណើនោះ។

មាត្រា៤
ទម្រង់និងខ្លឹមសារនៃសំណើ

១-សំណើសុំជំនួយផ្នែកច្បាប់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ភាគីទទួលសំណើត្រូវទទួលយកសំណើមកអនុវត្តភ្លាម ក្រោយពេលដែលបានផ្ញើជូនតាមទូរលេខ ទូរសារ សារអេឡិចត្រូនិកឬមធ្យោបាយទំនាក់ទំនងដទៃទៀត ដោយភាគីធ្វើសំណើត្រូវបញ្ជូនឯកសារសំណើច្បាប់ដើមតាមក្រោយឲ្យបានឆាប់រហ័ស។ ភាគីទទួលសំណើត្រូវជូនដំណឹងទៅភាគីធ្វើសំណើ អំពីលទ្ធផលនៃការអនុវត្តសំណើ ចំពោះតែក្នុងករណីដែលភាគីទទួលសំណើ បានទទួលនូវសំណើច្បាប់ដើមប៉ុណ្ណោះ។

២-សំណើសុំជំនួយផ្នែកច្បាប់ត្រូវមាន៖

ក- ឈ្មោះអាជ្ញាធរមានសមត្ថកិច្ចដែលស្នើសុំជំនួយផ្នែកច្បាប់

ខ- គោលបំណងនៃសំណើនិងការរៀបរាប់អំពីជំនួយផ្នែកច្បាប់ដែលបានស្នើសុំ

គ- ការរៀបរាប់អំពីបទល្មើស ទាក់ទងទៅនឹងការស៊ើបអង្កេតឬដំណើរការនីតិវិធីបណ្តឹងដែលបានអនុវត្ត គុណវុឌ្ឍិផ្នែកច្បាប់ បទបញ្ញត្តិច្បាប់ដែលអាចយកមកអនុវត្តបាន អត្ថបទច្បាប់ពាក់ព័ន្ធ ដែលអាច ផ្តន្ទាទោសបានចំពោះបទល្មើសព្រហ្មទណ្ឌនិងក្នុងករណីចាំបាច់ក៏ត្រូវបញ្ជាក់ផងដែរអំពីចរិតលក្ខណៈនិងវិសាលភាពនៃការខាតបង់ឬព្យសនកម្មដែលបានបង្កឡើងដោយសារបទល្មើសនេះ។

ឃ-មូលហេតុសម្រាប់ការប្រើប្រាស់និងការរៀបរាប់អំពីនីតិវិធីជាក់លាក់ទាំងឡាយណាដែលភាគីស្នើសុំចង់ឲ្យអនុវត្តតាម នៅក្នុងការអនុវត្តសំណើ

ង- ទិន្នន័យដែលកំណត់អត្តសញ្ញាណបុគ្គលជាកម្មវត្ថុនៃការស៊ើបអង្កេតឬដំណើរការនីតិវិធី

ច- ពេលវេលាកំណត់ណាមួយដែលភាគីស្នើសុំចង់ឲ្យអនុវត្តស្របទៅតាមសំណើ

ឆ- ឈ្មោះពេញ(ឈ្មោះ នាមខ្លួន នាមត្រកូលឬឈ្មោះកណ្តាល ប្រសិនបើមាន)និងអាសយដ្ឋាននិងប្រសិនបើអាចសូមផ្តល់ផងដែរនូវលេខទូរស័ព្ទរបស់បុគ្គលដែលត្រូវជូនដំណឹងនិងទំនាក់ទំនងរបស់ពួកគេទៅនឹងការងារស៊ើបអង្កេតឬដំណើរការនីតិវិធីដែលកំពុងបន្ត

ជ- ការចង្អុលបង្ហាញអំពីទីតាំងនិងការរៀបរាប់អំពីទីកន្លែង ដែលត្រូវធ្វើការត្រួតពិនិត្យនិងឆែកឆេរ ព្រមទាំងការបង្ហាញនិងការរៀបរាប់អំពីវត្ថុដែលត្រូវដកហូត

ឈ- សំណួរដែលត្រូវសួរដើម្បីប្រមូលភស្តុតាងពីសាក្សីនិងបុគ្គលដទៃទៀត

ញ-ក្នុងករណីដែលមានការបង្ហាញឲ្យដឹងថា ត្រូវការឲ្យមានវត្តមានរបស់អ្នកតំណាងអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីធ្វើសំណើ ត្រូវបញ្ជាក់អំពីឈ្មោះពេញនិងតួនាទីផ្លូវការ ព្រមទាំងមូលដ្ឋានថាហេតុអ្វីបានជាត្រូវការឲ្យមានវត្តមានរបស់ពួកគេ

ដ- ចំពោះសំណើដែលបានទទួល ត្រូវរក្សាការសម្ងាត់ចំពោះខ្លឹមសារនិង/ឬ ចំណាត់ការ ទាំងឡាយណាដែលត្រូវបានធ្វើឡើងទាក់ទងនឹងសំណើ ប្រសិនបើមានតម្រូវការចាំបាច់ឲ្យរក្សាការសម្ងាត់។

ឋ- ព័ត៌មានដទៃទៀតដែលអាចមានសារប្រយោជន៍ចំពោះភាគីទទួលសំណើ ដើម្បីអនុវត្តសំណើ។

៣-ប្រសិនបើភាគីទទួលសំណើពិចារណាឃើញថា ព័ត៌មានដែលមាននៅក្នុងសំណើនោះ មិនគ្រប់គ្រាន់សម្រាប់យកមកអនុវត្តសំណើនោះបាន ភាគីទទួលសំណើអាចស្នើសុំព័ត៌មានបន្ថែមបាន។

៤-សំណើជួយគ្នាទៅវិញទៅមក អាចរួមមាន៖

ក-ក្នុងករណីសំណើសុំយកភស្តុតាង ធ្វើការឆែកឆេរនិងដកហូតឬសំណើសុំទីតាំង ឃាត់ទុកឬរឹបអូសផលនៃបទល្មើស ត្រូវការឲ្យមានចម្លើយដែលបង្ហាញអំពីមូលដ្ឋាន ដើម្បីឲ្យជឿថាភស្តុតាងឬផលនៃបទល្មើស អាចរកឃើញនៅក្នុងទឹកដីរបស់ភាគីទទួលសំណើ។

ខ-ក្នុងករណីសំណើសុំយកភស្តុតាងត្រូវការឲ្យមានព័ត៌មាន ថាតើភស្តុតាងនេះនឹងតម្រូវឲ្យផ្តល់សម្បថ បញ្ជាក់ឬយកទៅប្រើប្រាស់តែម្តង ដូចមានកំណត់ចែងក្នុងច្បាប់របស់ភាគីធ្វើសំណើ។

គ-ក្នុងករណីសំណើសុំខ្ចីវត្ថុតាង ត្រូវការឲ្យមានព័ត៌មានអំពីទីតាំងបច្ចុប្បន្នរបស់វត្ថុតាងនៅក្នុងទឹកដីរបស់ភាគីទទួលសំណើនិងការចង្អុលបង្ហាញអំពីបុគ្គលដែលនឹងក្លាយជាអ្នកគ្រប់គ្រងថែរក្សាវត្ថុតាងទាំងនោះនៅក្នុងប្រទេសរបស់ភាគីធ្វើសំណើ កន្លែងដែលត្រូវបញ្ជូនវត្ថុតាង ការវិភាគដែលនឹងត្រូវធ្វើឡើងទៅលើវត្ថុតាង និងកាលបរិច្ឆេទបញ្ជូនវត្ថុតាងត្រឡប់ទៅឲ្យភាគីទទួលសំណើវិញ។

ឃ-ក្នុងករណីសំណើសុំចាត់វិធានការរឹតបន្តឹងចំពោះការដកហូតផលនៃបទល្មើសឬមធ្យោបាយប្រព្រឹត្តបទល្មើស៖

១-ការរៀបរាប់លម្អិតអំពីផលនៃបទល្មើសឬមធ្យោបាយប្រព្រឹត្តបទល្មើស ដោយរាប់បញ្ចូលទាំងទីតាំងរបស់ផលនៃបទល្មើសឬមធ្យោបាយប្រព្រឹត្តបទល្មើសទាំងនោះផងដែរ

២-ព័ត៌មានដែលផ្តល់នូវមូលដ្ឋានដើម្បីឲ្យជឿថាទ្រព្យសម្បត្តិទាំងនោះគឺជាផលនៃបទល្មើសឬមធ្យោបាយប្រព្រឹត្តបទល្មើស

៣-ការពណ៌នាអំពីភស្តុតាងដែលនឹងក្លាយជាកម្មវត្ថុនៃការសាកសួរនៅក្នុងដំណើរការនីតិវិធីតុលាការរបស់ភាគីធ្វើសំណើ។

មាត្រា៥
ភាសា

សំណើសុំជំនួយផ្នែកច្បាប់ ឯកសារភ្ជាប់ជាមួយសំណើ និងព័ត៌មានបន្ថែមដែលត្រូវបានបញ្ជូនស្រប តាមសន្ធិសញ្ញានេះ ត្រូវភ្ជាប់ជាមួយការបកប្រែជាភាសារបស់ភាគីទទួលសំណើឬជាភាសាអង់គ្លេស។ នីតិវិធី ដូចគ្នានេះ ក៏ត្រូវអនុវត្តចំពោះឯកសារនិងព័ត៌មានដែលត្រូវបានបញ្ជូនដើម្បីឆ្លើយតបនឹងសំណើបែបនេះផង ដែរ។

មាត្រា៦
ការបដិសេធឬការពន្យារពេលឆ្លើយតបចំពោះសំណើ

១- ជំនួយផ្នែកច្បាប់អាចត្រូវបានបដិសេធ ប្រសិនបើ៖

ក- ការអនុវត្តសំណើអាចប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឬ ផលប្រយោជន៍សំខាន់ៗដទៃទៀតរបស់ភាគីទទួលសំណើ

ខ- ការអនុវត្តសំណើផ្ទុយទៅនឹងច្បាប់របស់ភាគីទទួលសំណើឬមិនស្របទៅនឹងបញ្ញត្តិនៃ សន្ធិសញ្ញានេះ។

គ-សំណើទាក់ទងនឹងបទល្មើសដែលចុងចោទនៃបទល្មើសព្រហ្មទណ្ឌ ក្នុងភាគីផ្ញើសំណើ ត្រូវ បានផ្តន្ទាទោសឬឲ្យរួចផុតពីការចោទប្រកាន់ នៅក្នុងទឹកដីរបស់ភាគីទទួលសំណើ ពាក់ព័ន្ធនឹងបទល្មើសដូច គ្នា។

ឃ-សំណើទាក់ទងនឹងបទល្មើសក្រោមច្បាប់យោធា ដែលមិនមែនជាបទល្មើសស្ថិតក្រោមច្បាប់ ព្រហ្មទណ្ឌទូទៅ។

ង-ភាគីទទួលសំណើមានមូលហេតុជាច្រើនក្នុងការជឿថា សំណើត្រូវបានធ្វើឡើងដើម្បីផ្តន្ទា ទោសបុគ្គលនោះ ក្រោមមូលដ្ឋាននៃជាតិសាសន៍ ភេទ ជំនឿ សាសនា ពលរដ្ឋ ប្រភពដើមនៃជាតិពន្ធុ ទំនាក់ ទំនងជាមួយក្រុមសង្គមជាក់លាក់ណាមួយ ការផ្តន្ទាទោសនយោបាយឬស្ថានភាពរបស់បុគ្គលនោះ អាចរង ភាពលម្អៀង ដោយសារមូលហេតុទាំងនេះ។

២-ការសម្ងាត់ធនាគារឬការសម្ងាត់ពន្ធដារមិនអាចជាមូលដ្ឋានបដិសេធចំពោះការផ្តល់ជំនួយផ្នែក ច្បាប់ឡើយ។

៣-ជំនួយផ្នែកច្បាប់អាចត្រូវបានភាគីទទួលសំណើ ពន្យារពេលឬបដិសេធ ប្រសិនបើការអនុវត្ត សំណើនេះអាចបង្កការជ្រៀតជ្រែកដល់ដំណើរការស៊ើបអង្កេតដែលកំពុងបន្តឬដំណើរការនីតិវិធីពាក់ព័ន្ធនឹង បញ្ហាព្រហ្មទណ្ឌនៅក្នុងដែនសមត្ថកិច្ចរបស់ភាគីទទួលសំណើ។

៤-មុនពេលសម្រេចពន្យារពេលឬបដិសេធអនុវត្តសំណើ ភាគីទទួលសំណើត្រូវពិចារណាថាតើអាចផ្តល់ជំនួយផ្នែកច្បាប់ក្រោមលក្ខខណ្ឌទាំងនេះបានដែរឬទេ ប្រសិនបើមានភាពចាំបាច់។ ប្រសិនបើរដ្ឋធ្វើសំណើទទួលយកជំនួយផ្នែកច្បាប់ក្រោមលក្ខខណ្ឌទាំងនេះ ភាគីធ្វើសំណើមានកាតព្វកិច្ចអនុវត្តឲ្យបានត្រឹមត្រូវ ស្របតាមលក្ខខណ្ឌដែលបានកំណត់។

៥-ភាគីទទួលសំណើត្រូវជូនដំណឹងដល់ភាគីធ្វើសំណើភ្លាមៗអំពីសេចក្តីសម្រេចរបស់ខ្លួនដែលមិនអនុវត្តស្របតាមសំណើសុំជំនួយទាំងស្រុងឬមួយផ្នែកឬពន្យារពេលអនុវត្ត និងត្រូវផ្តល់មូលហេតុចំពោះការសម្រេចបែបនេះ។

មាត្រា៧
សុពលភាពនៃឯកសារ

១-ឯកសារដែលត្រូវបានបញ្ជូនក្រោមមូលដ្ឋាននៃសន្ធិសញ្ញានេះនិងដែលមានការបញ្ជាក់ដោយការបោះត្រាពីអាជ្ញាធរមានសមត្ថកិច្ចឬអាជ្ញាធរកណ្តាលរបស់ភាគីបញ្ជូន អាចប្រើប្រាស់ជាភស្តុតាងបានដោយមិនចាំបាច់ត្រូវធ្វើការបញ្ជាក់បន្ថែមទៀត។

យោងតាមសំណើរបស់ភាគីធ្វើសំណើ ឯកសារដែលត្រូវបានបញ្ជូនក្រោមក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ អាចត្រូវបានបញ្ជាក់ក្នុងទម្រង់ដទៃទៀត ដូចដែលមានចង្អុលបង្ហាញនៅក្នុងសំណើ ដរាបណាការបញ្ជាក់ក្នុងទម្រង់ដទៃទៀតនោះ មិនផ្ទុយនឹងច្បាប់របស់ភាគីទទួលសំណើ។

២-សម្រាប់គោលបំណងនៃសន្ធិសញ្ញានេះនិងយោងតាមបញ្ញត្តិនៃមាត្រានេះ ឯកសារដែលត្រូវបានទទួលស្គាល់ថាជាឯកសារផ្លូវការនៅក្នុងទឹកដីរបស់ភាគីមួយ ក៏ត្រូវទទួលស្គាល់ថាជាឯកសារផ្លូវការនៅក្នុងទឹកដីរបស់ភាគីដទៃទៀតផងដែរ។

មាត្រា៨
ការសម្ងាត់និងភាពមានកម្រិតនៃការប្រើប្រាស់ព័ត៌មាន

១-ផ្អែកតាមសំណើពីអាជ្ញាធរកណ្តាលរបស់ភាគីធ្វើសំណើនិងយោងតាមបទបញ្ញត្តិរបស់ខ្លួនភាគីទទួលសំណើត្រូវរក្សាការសម្ងាត់អំពីការដែលខ្លួនបានទទួលសំណើសុំជំនួយផ្នែកច្បាប់ ខ្លឹមសារនៃសំណើ ឬចំណាត់ការណាមួយដែលត្រូវបានធ្វើឡើងទៅតាមសំណើ ដោយមិនរាប់បញ្ចូលករណីដែលការទម្លាយការសម្ងាត់នៃសំណើមានភាពចាំបាច់ដើម្បីអនុវត្តសំណើនេះ។

ប្រសិនបើការអនុវត្តសំណើធ្វើឲ្យមានភាពចាំបាច់ក្នុងការដកចេញនូវភាពមានកម្រិតទាំងនេះ ភាគីទទួលសំណើត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីធ្វើសំណើ និងប្រសិនបើគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីធ្វើសំណើទេនោះ ភាគីទទួលសំណើមិនអាចអនុវត្តសំណើបានឡើយ។

២-ភាគីធ្វើសំណើមិនត្រូវប្រើប្រាស់ព័ត៌មានឬភស្តុតាងដែលទទួលបានក្រោមសន្ធិសញ្ញានេះ ដោយគ្មានការអនុញ្ញាតពីភាគីទទួលសំណើ ក្នុងគោលបំណងដទៃទៀតក្រៅពីគោលបំណងដែលបានចង្អុលបង្ហាញនៅក្នុងសំណើផ្តល់ជំនួយផ្នែកច្បាប់ឡើយ។

៣-ក្នុងករណីដែលភាគីធ្វើសំណើត្រូវការបង្ហាញនិងប្រើប្រាស់ទាំងស្រុងឬមួយផ្នែកនៃព័ត៌មានឬភស្តុតាងសម្រាប់គោលបំណងដទៃទៀតក្រៅពីគោលបំណងដែលមានចែងក្នុងសំណើនេះ ភាគីធ្វើសំណើត្រូវសុំការយល់ព្រមពីភាគីទទួលសំណើ ដោយភាគីទទួលសំណើអាចយល់ព្រមឬបដិសេធទាំងស្រុងឬមួយផ្នែកចំពោះការអនុញ្ញាតឲ្យប្រើប្រាស់ក្នុងគោលបំណងទាំងនោះទៅតាមករណីជាក់ស្តែង។

មាត្រា៩
ការអនុវត្តសំណើ

១-សំណើសុំជំនួយផ្នែកច្បាប់ត្រូវអនុវត្តស្របតាមច្បាប់របស់ភាគីទទួលសំណើនិងបញ្ញត្តិនៃសន្ធិសញ្ញានេះ។

យោងតាមសំណើរបស់ភាគីធ្វើសំណើភាគីទទួលសំណើត្រូវផ្តល់ជំនួយផ្នែកច្បាប់ទៅតាមទម្រង់និងនីតិវិធីពិសេសនានា ដែលមានបញ្ជាក់នៅក្នុងសំណើ ដរាបណាវាមិនផ្ទុយទៅនឹងច្បាប់របស់ភាគីទទួលសំណើ។

២-ប្រសិនបើភាគីធ្វើសំណើត្រូវការឲ្យមានវត្តមានអ្នកតំណាងអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនក្នុងពេលអនុវត្តសំណើភាគីទទួលសំណើត្រូវជូនដំណឹងទៅភាគីធ្វើសំណើអំពីសេចក្តីសម្រេចរបស់ខ្លួន។

ក្នុងករណីភាគីទទួលសំណើធ្វើការសម្រេចចិត្តជាវិជ្ជមាន ភាគីធ្វើសំណើនឹងត្រូវទទួលបានការជូនដំណឹងជាមុន អំពីពេលវេលា ទីកន្លែងនៃការអនុវត្តសំណើ។

៣-អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ ត្រូវបញ្ជូនព័ត៌មាននិងភស្តុតាងដែលបានទទួលសម្រាប់ឆ្លើយតបទៅនឹងសំណើ ទៅឲ្យអាជ្ញាធរកណ្តាលនៃភាគីធ្វើសំណើ ក្នុងរយៈពេលមួយដែលសមស្រប។

៤-ប្រសិនបើមិនអាចអនុវត្តសំណើទាំងមូលឬមួយផ្នែកបានទេនោះ អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ ត្រូវជូនដំណឹងភ្លាមៗទៅអាជ្ញាធរកណ្តាលនៃភាគីធ្វើសំណើអំពីការដែលមិនអាចអនុវត្តសំណើ បាន ដោយបញ្ជាក់ពីហេតុផល។

មាត្រា១០
សេវាកម្មឯកសារ

១-យោងតាមសំណើសុំជំនួយផ្នែកច្បាប់ អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ ត្រូវធ្វើការចាត់ចែង ឬរៀបចំភ្លាមៗនូវសេវាឯកសារ តាមរយៈអាជ្ញាធរមានសមត្ថកិច្ច។

២-ភាគីធ្វើសំណើត្រូវបញ្ជូនសំណើសុំឯកសារពាក់ព័ន្ធនឹងការឆ្លើយតបឬការបង្ហាញខ្លួននៅក្នុងទឹកដីរបស់ភាគីធ្វើសំណើ ក្នុងរយៈពេលមួយសមស្រប មុនពេលឆ្លើយតបឬការបង្ហាញខ្លួនដែលបានកំណត់ជាធម្មតាគឺមិនយឺតជាងរយៈពេល ៦០ថ្ងៃ មុនពេលបង្ហាញខ្លួន។

៣-អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើត្រូវផ្ញើភស្តុតាងបញ្ជាក់អំពីការបញ្ជូនឯកសារដោយអនុលោមទៅតាមច្បាប់និងនីតិវិធីរបស់ខ្លួន។ ភស្តុតាងបញ្ជាក់អំពីការបញ្ជូនឯកសារនេះត្រូវបង្ហាញអំពីកាលបរិច្ឆេទ ហត្ថលេខារបស់អ្នកទទួលដីកានិង/ឬសេចក្តីថ្លែងការណ៍របស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ ទៅតាមករណីជាក់ស្តែង ដោយបញ្ជាក់អំពីហេតុការនៃការបញ្ជូនឯកសារ កាលបរិច្ឆេទ និងរបៀបនៃការបញ្ជូនឯកសារ។

មាត្រា១១
ការយកភស្តុតាង

១-ក្នុងករណីដែលសំណើមួយត្រូវបានធ្វើឡើង ដើម្បីសុំភស្តុតាងសម្រាប់គោលបំណងស៊ើបអង្កេតឬដំណើរការនីតិវិធីទាក់ទងនឹងវិស័យព្រហ្មទណ្ឌ នៅក្នុងយុត្តាធិការរបស់ភាគីធ្វើសំណើ ភាគីទទួលសំណើត្រូវរៀបចំសម្រាប់ផ្តល់ជូននូវភស្តុតាងទាំងនោះ។

២-សម្រាប់គោលបំណងនៃសន្ធិសញ្ញានេះ ការផ្តល់ឲ្យឬការយកភស្តុតាងរួមមាន សក្ខីកម្មរបស់សាក្សី ជនរងគ្រោះ ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌ សេចក្តីសន្និដ្ឋានរបស់អ្នកឯកទេស ការផលិតឯកសារ អត្ថបទឬកំណត់ហេតុ។

៣-អ្នកតំណាងនៃអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីធ្វើសំណើដែលមានវត្តមាននៅពេលអនុវត្តសំណើត្រូវទទួលបានការអនុញ្ញាតិ្តឲ្យរៀបចំសំណួរ ដែលអាចសួរដេញដោលបុគ្គលសាមីបាន តាមរយៈអ្នកតំណាងនៃអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ។

៤-ភាគីធ្វើសំណើត្រូវពិនិត្យលក្ខខណ្ឌនានាដែលភាគីទទួលសំណើបានកំណត់ទាក់ទងទៅនឹងឯកសារនិងវត្ថុនានាដែលអាចត្រូវផ្តល់ជូនទៅឱ្យភាគីទទួលសំណើរួមទាំងលក្ខខណ្ឌសម្រាប់ការពារប្រយោជន៍ភាគីទី៣ នៅក្នុងឯកសារនិងវត្ថុទាំងនោះផងដែរ។

៥-បុគ្គលម្នាក់ដែលតម្រូវឲ្យផ្តល់ភស្តុតាងនៅក្នុងទឹកដីរបស់ភាគីទទួលសំណើ ក្រោមមូលដ្ឋាននៃសំណើសុំជំនួយ អាចបដិសេធក្នុងការធ្វើបែបនេះ ក្នុងករណីដូចខាងក្រោម៖

ក- ច្បាប់របស់ភាគីទទួលសំណើ អនុញ្ញាតឲ្យបុគ្គលនោះបដិសេធផ្តល់ភស្តុតាងក្នុងស្ថានភាពស្រដៀងគ្នា នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលអាចផ្តួចផ្តើមពីដំបូងនៅក្នុងភាគីទទួលសំណើ។

ខ- ច្បាប់របស់ភាគីធ្វើសំណើ អនុញ្ញាតឲ្យបុគ្គលនោះបដិសេធក្នុងការផ្តល់ភស្តុតាងនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងទឹកដីរបស់ភាគីធ្វើសំណើ។

៦-ប្រសិនបើមានបុគ្គលណាម្នាក់អះអាងថាមានសិទ្ធិបដិសេធចំពោះការផ្តល់ភស្តុតាងក្រោមច្បាប់របស់ភាគីធ្វើសំណើ ភាគីទទួលសំណើដោយគោរពតាមការកំណត់ចែងយ៉ាងដូច្នេះ អាចផ្អែកលើឯកសាររបស់អាជ្ញាធរកណ្តាលនៃភាគីធ្វើសំណើ ដើម្បីប្រើប្រាស់ជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបានសម្រាប់មូលដ្ឋានច្បាប់នៃការទាមទារបែបនេះ។

មាត្រា១២
ការផ្តល់ព័ត៌មាន ឯកសារ និងកំណត់ហេតុ

១-ភាគីទទួលសំណើត្រូវផ្តល់ឲ្យភាគីធ្វើសំណើនូវច្បាប់ចម្លងនៃឯកសារ កំណត់ហេតុ និងព័ត៌មានរបស់ក្រសួងនិងស្ថាប័នដែលឯកសារទាំងនេះអាចរកបានជាសាធារណៈយោងតាមច្បាប់របស់ខ្លួន។

២-ភាគីទទួលសំណើអាចផ្តល់ឲ្យភាគីធ្វើសំណើនូវរាល់ព័ត៌មាន ឯកសារ និងកំណត់ហេតុនានារបស់ក្រសួងនិងភ្នាក់ងាររដ្ឋាភិបាលណាមួយ ដែលមិនមែនជាឯកសារសាធារណៈ លើកលែងតែឯកសារដែលផ្ទុកនូវទិន្នន័យសម្ងាត់របស់រដ្ឋ ដោយឯកសារសម្ងាត់បែបនេះត្រូវគ្រប់គ្រងក្នុងលក្ខណៈដូចគ្នានិងក្រោមលក្ខខណ្ឌដូចគ្នាចំពោះការផ្តល់ជូនទៅឲ្យមន្ត្រីអនុវត្តច្បាប់និងតុលាការរបស់ភាគីទទួលសំណើ។

មាត្រា១៣
ការឆែកឆេរនិងការដកហូត

១-ដរាបណាច្បាប់អនុញ្ញាត ភាគីទទួលសំណើត្រូវអនុវត្តសំណើធ្វើការឆែកឆេរ ដកហូត និងប្រគល់សម្ភារៈទៅឲ្យភាគីធ្វើសំណើ ដែលសម្ភារៈទាំងនោះពាក់ព័ន្ធទៅនឹងការងារស៊ើបអង្កេតឬដំណើរការនីតិវិធីដទៃទៀតទាក់ទងទៅនឹងវិស័យព្រហ្មទណ្ឌដែលកំពុងរង់ចាំការកាត់សេចក្តីនៅក្នុងភាគីធ្វើសំណើ។ សំណើបែបនេះត្រូវផ្អែកលើមូលដ្ឋានសមស្រប។

២-ភាគីទទួលសំណើត្រូវផ្តល់ព័ត៌មានបែបនេះទៅតាមការស្នើសុំពីភាគីធ្វើសំណើ ដែលព័ត៌មាននោះពាក់ព័ន្ធនឹងលទ្ធផលនៃការឆែកឆេរ ទីកន្លែងនៃការដកហូត ស្ថានភាពនៃការដកហូត និងការរក្សាទុកសម្ភារៈដែលបានដកហូត។

មាត្រា១៤
ទីតាំងនិងអត្តសញ្ញាណរបស់មនុស្សនិងវត្ថុ

ដូចមានចែងនៅក្នុងច្បាប់របស់ខ្លួន អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ ត្រូវខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទីតាំងនិងអត្តសញ្ញាណរបស់មនុស្សនិងវត្ថុដែលបានកំណត់នៅក្នុងសំណើ។

មាត្រា១៥
ការបង្ហាញខ្លួនដោយផ្ទាល់របស់សាក្សី ជនរងគ្រោះ និងអ្នកជាប់ចោទនៅក្នុងទឹកដីរបស់ភាគីធ្វើសំណើ

១-ប្រសិនបើភាគីធ្វើសំណើ ដាក់ជូននូវសំណើមួយដែលស្នើឲ្យមានការបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីស្នើសុំដោយផ្ទាល់ ដើម្បីបង្ហាញ ភស្តុតាង ធ្វើកោសល្យវិច័យឬដើម្បីអនុវត្តវិធានការនីតិវិធីដទៃទៀតនៅក្នុងទឹកដីរបស់ខ្លួន ភាគីទទួលសំណើត្រូវជូនដំណឹងដល់សាមីជន។

២-សំណើសុំឲ្យបុគ្គលបង្ហាញខ្លួនខាងលើនេះ ត្រូវមានព័ត៌មានអំពីលក្ខខណ្ឌនិងសេចក្តីតម្រូវនានាដើម្បីគ្របដណ្តប់លើថ្លៃចំណាយពាក់ព័ន្ធនឹងការបង្ហាញខ្លួនរបស់បុគ្គលដែលត្រូវបានកោះហៅនិងបញ្ជីរាយនាម ការធានាមួយចំនួនដែលបុគ្គលរូបនេះមានសិទ្ធិទទួលបានក្រោមមាត្រា១៦នៃសន្ធិសញ្ញានេះ។

៣-សំណើសុំឲ្យបុគ្គលបង្ហាញខ្លួនខាងលើនេះមិនត្រូវបញ្ចូលការគំរាមកំហែងណាមួយថានឹងប្រើប្រាស់វិធានការបង្ខំឬកំណត់ទោស ក្នុងករណីបុគ្គលរូបនោះខកខានក្នុងការបង្ហាញខ្លួននៅក្នុងទឹកដីរបស់ភាគីធ្វើសំណើឡើយ។

៤-បុគ្គលដែលត្រូវបានកោះហៅត្រូវសម្រេចចិត្តបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។ អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ ត្រូវជូនដំណឹងដល់អាជ្ញាធរកណ្តាលនៃភាគីធ្វើសំណើភ្លាមៗ អំពីការឆ្លើយតបរបស់បុគ្គលនោះ។

មាត្រា១៦
សុវត្ថិភាព

១-បុគ្គលដែលចូលបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងភាគីធ្វើសំណើ មិនចំពោះថាជាពលរដ្ឋអ្វីឡើយ មិនត្រូវបានឃុំខ្លួនឬក្លាយជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌឬការរឹតបន្តឹងក្នុងទម្រង់ដទៃទៀតទៅលើសេរីភាពផ្ទាល់ខ្លួននៅក្នុងទឹកដីរបស់ភាគីធ្វើសំណើ ដោយសារតែសកម្មភាពណាមួយឬ

ក្រោមមូលដ្ឋាននៃការផ្តន្ទាទោស ដែលបានកើតឡើងមុនពេលបុគ្គលនោះចូលទៅក្នុងទឹកដីរបស់ភាគីផ្ញើសំណើឡើយ។ប្រសិនបើការធានាបែបនេះ មិនអាចផ្តល់ជូនបានដោយសារតែហេតុផលណាមួយ អាជ្ញាធរកណ្តាលនៃភាគីផ្ញើសំណើត្រូវបញ្ជាក់អំពីចំណុចនេះនៅក្នុងសំណើ ដើម្បីជូនដំណឹងដល់បុគ្គលដែលជាកម្មវត្ថុនៃសំណើនិងដើម្បីអនុញ្ញាតឲ្យបុគ្គលរូបនោះធ្វើការសម្រេចចិត្តថាតើគួរចូលបង្ហាញខ្លួនដែរឬទេ ដោយពិចារណាអំពីស្ថានភាពទាំងនេះ។

២-បុគ្គលដែលត្រូវបានកោះហៅ ត្រូវបាត់បង់សិទ្ធិដែលមិនអាចរំលោភបំពានបានរបស់ខ្លួន ដូចមានកំណត់ចែងនៅក្នុងកថាខណ្ឌ១នៃមាត្រានេះ ប្រសិនបើបុគ្គលនោះដែលកំពុងមានសេរីភាពអាចចាកចេញពីទឹកដីរបស់ភាគីផ្ញើសំណើ ប៉ុន្តែបែរជាមិនបានចាកចេញក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ចថាលែងត្រូវការឲ្យមានវត្តមានរបស់បុគ្គលរូបនោះ ឬបានចាកចេញពីទឹកដីនោះឬបានវិលត្រឡប់មកវិញដោយស្ម័គ្រចិត្ត។

៣-បុគ្គលដែលត្រូវបានកោះហៅមិនត្រូវបានបង្ខំឲ្យបង្ហាញភស្តុតាងនៅក្នុងករណីដទៃទៀត ក្រៅពីករណីដូចមានបញ្ជាក់នៅក្នុងសំណើឡើយ។

មាត្រា១៧
ការផ្ទេរជាបណ្តោះអាសន្នចំពោះបុគ្គលដែលកំពុងជាប់ឃុំ
(រាប់បញ្ចូលបុគ្គលទាំងឡាយណាដែលកំពុងទទួលទោសក្នុងទម្រង់ជាការជាប់ពន្ធនាគារ)

១-ដោយមានការយល់ព្រមពីអាជ្ញាធរកណ្តាលនៃភាគីទទួលសំណើបុគ្គលដែលកំពុងជាប់ឃុំ(រាប់បញ្ចូលទាំងបុគ្គលដែលកំពុងទទួលទោសក្នុងទម្រង់ជាការជាប់ពន្ធនាគារ) មិនចំពោះថាជាពលរដ្ឋអ្វីឡើយ អាចត្រូវបានផ្ទេរជាបណ្តោះអាសន្នទៅភាគីផ្ញើសំណើ ដើម្បីផ្តល់ភស្តុតាងក្នុងនាមជាសាក្សីឬជនរងគ្រោះឬ ដើម្បីផ្តល់ជំនួយនៅក្នុងដំណើរការនីតិវិធីដទៃទៀត ដូចមានបញ្ជាក់នៅក្នុងសំណើ ដរាបណាបុគ្គលរូបនោះត្រូវបានបញ្ជូនត្រឡប់ទៅភាគីទទួលសំណើវិញក្នុងរយៈពេលដែលបានកំណត់។

រយៈពេលដំបូងដែលគេអាចត្រូវធ្វើការបញ្ជូនបុគ្គលរូបនេះមិនត្រូវលើសពី៩០ថ្ងៃឡើយ។ យោងតាមសំណើរបស់អាជ្ញាធរកណ្តាលរបស់ភាគីផ្ញើសំណើនិងផ្អែកលើមូលដ្ឋានសំខាន់ៗមួយចំនួន រយៈពេលស្នាក់នៅរបស់បុគ្គលដែលត្រូវបានផ្ទេរអាចត្រូវបានពន្យារពេលស្នាក់នៅបន្តទៀតដោយអាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ។ ការពន្យារពេលស្នាក់នៅនីមួយៗមិនត្រូវលើសរយៈពេល៩០ថ្ងៃឡើយ។

សេចក្តីបង្គាប់និងលក្ខខណ្ឌនៃការផ្ទេរនិងការបញ្ជូនបុគ្គលរូបនោះមកវិញ ត្រូវមានការសម្របសម្រួលពីអាជ្ញាធរកណ្តាលរបស់គូភាគី។

២-ការផ្ទេរបុគ្គលរូបនេះអាចត្រូវបានបដិសេធឬពន្យារពេលទៅតាមករណីជាក់ស្តែងៈ

ក- ប្រសិនបើបុគ្គលជាប់ឃុំ(រាប់បញ្ចូលបុគ្គលដែលកំពុងទទួលទោសក្នុងទម្រង់ជាការជាប់ពន្ធនាគារ) មិនបានផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរចំពោះការផ្ទេរនេះ។

ខ- ប្រសិនបើការចូលរួមរបស់បុគ្គលម្នាក់នេះក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅក្នុងទឹកដីរបស់ភាគីទទួលសំណើមានភាពចាំបាច់។

៣-ភាគីផ្ញើសំណើត្រូវរក្សាទុកបុគ្គលដែលត្រូវបានផ្ទេរឲ្យស្ថិតនៅក្នុងការឃុំឃាំង ដរាបណាសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើឲ្យឃុំខ្លួនបុគ្គលរូបនោះនៅតែបន្តស្ថិតនៅជាធរមាន។

ក្នុងករណីដោះលែងបុគ្គលជាប់ឃុំ ត្រូវបានធ្វើឡើងដោយសេចក្តីសម្រេចរបស់ភាគីទទួលសំណើ ភាគីផ្ញើសំណើត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា១៥ មាត្រា១៦និងមាត្រា១៩នៃសន្ធិសញ្ញានេះដែលពាក់ព័ន្ធនឹងករណីបុគ្គលរូបនោះ។

៤-រយៈពេលដែលបុគ្គលជាប់ឃុំដែលត្រូវបានផ្ទេរទៅឲ្យភាគីផ្ញើសំណើ ត្រូវចាត់ទុកថាជាការជាប់ទោស/ឃុំឃាំង នៅក្នុងទឹកដីរបស់ភាគីទទួលសំណើនិងមានតម្លៃស្មើទៅនឹងរយៈពេលជាប់ទោសឬឃុំឃាំងនៅក្នុងប្រទេសរបស់ភាគីផ្ញើសំណើ។

៥-ប្រសិនបើបុគ្គលដែលត្រូវឃុំខ្លួន(រួមបញ្ចូលទាំងបុគ្គលកំពុងអនុវត្តទោសក្នុងពន្ធនាគារ)បដិសេធមិនបង្ហាញខ្លួនចំពោះភាគីផ្ញើសំណើដោយមូលហេតុណាមួយ បុគ្គលនោះមិនត្រូវបានបង្ខិតបង្ខំឬការពិន័យណាមួយឡើយ។

មាត្រា១៨
ការដោះដូរព័ត៌មានអំពីការផ្តន្ទាទោសនិងកំណត់ហេតុតុលាការ

១-ជារៀងរាល់ឆ្នាំ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានអំពីការផ្តន្ទាទោសដែលសម្រេចដោយតុលាការរបស់ខ្លួន ពាក់ព័ន្ធនឹងពលរដ្ឋរបស់ភាគីម្ខាងទៀត។

២-ភាគីនីមួយៗត្រូវផ្តល់ជូនដោយឥតគិតថ្លៃដល់ភាគីម្ខាងទៀត នៅពេលមានសំណើសុំព័ត៌មានអំពីការផ្តន្ទាទោសកន្លងមករបស់ទណ្ឌិត ប្រសិនបើទណ្ឌិតទាំងនោះមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងទឹកដីរបស់ភាគីផ្ញើសំណើ។

មាត្រា១៩
កិច្ចការពារបុគ្គលដែលចូលបង្ហាញខ្លួនតាមការស្នើសុំឬត្រូវបានផ្ទេរទៅទឹកដីរបស់ភាគីទទួលសំណើ

ក្នុងករណីចាំបាច់ ភាគីផ្ញើសំណើត្រូវផ្តល់កិច្ចការពារដល់បុគ្គលដែលចូលបង្ហាញខ្លួនតាមការស្នើសុំដូចមានចែងក្នុងមាត្រា១៥ ឬបុគ្គលដែលត្រូវបានផ្ទេរទៅទឹកដីរបស់ខ្លួនដូចមានចែងក្នុងមាត្រា១៧នៃសន្ធិសញ្ញានេះ។

មាត្រា២០
ករណីពិសេសនៃការផ្តល់ជំនួយផ្នែកច្បាប់

ភាគីទទួលសំណើអាចផ្តល់ជូនទៅតាមសំណើសុំនូវការដកស្រង់ពីសំណុំរឿងព្រហ្មទណ្ឌនិង/ឬឯកសារ និងអត្ថបទទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌទាំងនោះ ដែលមានភាពចាំបាច់សម្រាប់ការងារស៊ើបអង្កេតនិង/ឬ ដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ អាចទទួលបានឯកសារនិង អត្ថបទទាំងនោះនៅក្នុងសំណុំរឿងស្រដៀងគ្នា លើកលែងតែឯកសារឬអត្ថបទដែលរួមមានការសម្ងាត់របស់រដ្ឋ។

មាត្រា២១
ផលនៃបទល្មើសនិងមធ្យោបាយប្រព្រឹត្តបទល្មើស

១-យោងតាមច្បាប់របស់ខ្លួន គូភាគីត្រូវជួយគ្នាទៅវិញទៅមកក្នុងការស្វែងរក ឃាត់ទុក បង្កក និង រឹបអូសទ្រព្យសម្បត្តិខុសច្បាប់នានា ផលនៃបទល្មើស ព្រមទាំងមធ្យោបាយប្រព្រឹត្តបទល្មើស ក្នុងគោលបំណង ដកហូតនិងផ្តល់សំណងជូនជនរងគ្រោះនៃបទល្មើស។

២-ប្រសិនបើអាជ្ញាធរកណ្តាលនៃភាគីណាមួយបានដឹងថាផលនៃបទល្មើសនិងមធ្យោបាយប្រព្រឹត្ត បទល្មើសដែលអាចជាកម្មវត្ថុនៃការដកហូត ស្ថិតក្នុងទឹកដីរបស់ភាគីម្ខាងទៀត ភាគីនោះត្រូវជូនដំណឹងដល់ អាជ្ញាធរកណ្តាលនៃភាគីមួយទៀត ដើម្បីចាត់វិធានការសមស្របដូចមានចែងក្នុងមាត្រានេះ ។ អាជ្ញាធរកណ្តាលដែល បានទទួលព័ត៌មាននេះត្រូវជូនដំណឹងដល់អាជ្ញាធរកណ្តាលដែលបានផ្តល់ព័ត៌មានអំពីចំណាត់ការដែលបានអនុវត្ត។

៣-អាជ្ញាធរកណ្តាលនៃគូភាគីត្រូវធ្វើការកំណត់រួមគ្នាទៅតាមករណីនីមួយៗអំពីលទ្ធភាពនៃការផ្ទេរ ទាំងស្រុងឬមួយផ្នែកចំពោះមធ្យោបាយប្រព្រឹត្តបទល្មើសនិងផលនៃបទល្មើស ព្រមទាំងផលដែលទទួលបាន ពីការលក់របស់ទាំងអស់នោះទៅឲ្យភាគីម្ខាងទៀត ដោយរាប់បញ្ចូលសម្រាប់គោលបំណងដកហូតនិងផ្តល់ សំណងទៅតាមការដែលច្បាប់របស់ខ្លួនអនុញ្ញាត និងក្នុងកម្រិតវិសាលភាពដែលយល់ឃើញថា សមស្រប នៅពេលដែលមានសាលក្រមស្ពាពដែលចេញដោយតុលាការរបស់ភាគីធ្វើសំណើ។ ក្រោយពេលដែលសន្ធិសញ្ញា នេះមានអានុភាពអនុវត្ត គូភាគីត្រូវពិចារណាអំពីលទ្ធភាពធ្វើការចាត់ចែងសមស្របពាក់ព័ន្ធនឹងបញ្ហាការដក ហូតផលនៃបទល្មើសនិងមធ្យោបាយប្រព្រឹត្តបទល្មើស ព្រមទាំងការទុកដាក់ផលនិងមធ្យោបាយទាំងនោះ។

មាត្រា២២
ការចំណាយ

១-ភាគីទទួលសំណើត្រូវទទួលបន្ទុកលើរាល់ការចំណាយជាប្រក្រតីនៃការអនុវត្តសំណើសុំជំនួយ ផ្នែកច្បាប់លើកលែងតែខ្ទង់ចំណាយខាងក្រោមដែលភាគីធ្វើសំណើត្រូវទទួលបន្ទុកៈ

ក- ចំណាយពាក់ព័ន្ធនឹងការបញ្ជូនបុគ្គលសាមីទៅទឹកដីរបស់ខ្លួននិងត្រឡប់ពីទឹកដីរបស់ខ្លួនវិញ ស្របតាមមាត្រា១៥និងមាត្រា១៧នៃសន្ធិសញ្ញានេះ ព្រមទាំងចំណាយពាក់ព័ន្ធនឹងវត្តមានរបស់ពួកគេនៅក្នុងទឹកដីនោះ និងការគ្របដណ្តប់លើថ្លៃចំណាយដទៃទៀត ដែលត្រូវផ្តល់ជូនបុគ្គលទាំងនោះ។ បុគ្គលម្នាក់ដែលយល់ព្រមចូលបង្ហាញខ្លួនអាចស្នើឲ្យភាគីធ្វើសំណើបញ្ចេញថវិកាជាមុន(បុរេប្រទាន)ដើម្បីគ្របដណ្តប់លើថ្លៃចំណាយទាំងនេះ។ ការបញ្ចេញថវិកាជាមុនបែបនេះអាចត្រូវបានផ្តល់ជូនតាមរយៈស្ថានទូតឬស្ថានកុងស៊ុលរបស់ភាគីធ្វើសំណើ។

ខ- ថ្លៃចំណាយនិងថ្លៃសេវាសម្រាប់អ្នកឯកទេស។

គ- ថ្លៃចំណាយពាក់ព័ន្ធនឹងការធ្វើដំណើរនិងវត្តមានរបស់អ្នកតំណាងអាជ្ញាធរមានសមត្ថកិច្ចនៃភាគីធ្វើសំណើសម្រាប់ការអនុវត្តសំណើដោយយោងទៅតាមកថាខណ្ឌ២នៃមាត្រា៩ នៃសន្ធិសញ្ញានេះ។

ឃ-ថ្លៃចំណាយពាក់ព័ន្ធនឹងការផ្ទេរវត្ថុនានាពីទឹកដីរបស់ភាគីទទួលសំណើទៅទឹកដីរបស់ភាគីធ្វើសំណើនិងការបញ្ជូនវត្ថុទាំងនោះត្រឡប់មកវិញ។

ង-ថ្លៃចំណាយពាក់ព័ន្ធនឹងការយកភស្តុតាងពីភាគីទទួលសំណើទៅភាគីធ្វើសំណើតាមរយៈវីដេអូផ្សាយរណបឬមធ្យោបាយបច្ចេកវិទ្យាដទៃទៀត។

២-ប្រសិនបើវាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាការចំណាយដែលត្រូវចេញដោយភាគីទទួលសំណើច្រើនហួសប្រមាណ គូភាគីត្រូវពិគ្រោះគ្នាដើម្បីកំណត់ទៅលើលក្ខខណ្ឌដែលជាមូលដ្ឋាននៃការផ្តល់ជំនួយដែលបានស្នើសុំ។

មាត្រា២៣
ការពិគ្រោះយោបល់និងការដោះស្រាយវិវាទ

១-យោងតាមសំណើរបស់ភាគីណាមួយ អាជ្ញាធរកណ្តាលត្រូវធ្វើការពិគ្រោះយោបល់ នៅពេលដែលមានការចាំបាច់ទាក់ទងនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញានេះជាទូទៅឬទាក់ទងនឹងសំណើជាក់លាក់ណាមួយ។

២-រាល់ការខ្វែងគំនិតគ្នាដែលកើតចេញពីការបកស្រាយឬការអនុវត្តសន្ធិសញ្ញានេះ ត្រូវដោះស្រាយដោយការចរចាតាមរយៈការទូត។

មាត្រា២៤
អវសានប្បញ្ញត្តិ

១-ដោយមានការឯកភាពគ្នារវាងគូភាគី សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មដោយការធ្វើវិសោធនកម្មបែបនេះ ត្រូវចូលជាធរមានស្របតាមនីតិវិធីដូចមានចែងនៅក្នុងកថាខណ្ឌ២នៃមាត្រានេះ។

២-សន្ធិសញ្ញានេះត្រូវចូលជាធរមាន ក្នុងរយៈពេល៩០ថ្ងៃក្រោយពេលកាលបរិច្ឆេទចុងក្រោយ ដែលគូភាគីបានទទួលពីការជូនដំណឹងគ្នាទៅវិញទៅមកតាមរយៈបណ្តាញការទូត បន្ទាប់ពីភាគីនីមួយៗបានបំពេញតាមលក្ខខណ្ឌអនុលោមតាមច្បាប់ជាតិរបស់ខ្លួន សម្រាប់ការចូលជាធរមាននៃសន្ធិសញ្ញានេះ។

៣-សន្ធិសញ្ញានេះត្រូវបញ្ចប់ក្នុងរយៈពេល១៨០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលភាគីណាមួយបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូត ពីភាគីម្ខាងទៀតអំពីចេតនារបស់ខ្លួនក្នុងការបញ្ចប់សន្ធិសញ្ញានេះ។

៤-ការបញ្ចប់សន្ធិសញ្ញានេះមិនត្រូវរារាំងដល់ការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ណាមួយដែលបានទទួលមុនពេលថ្ងៃបញ្ចប់នៃសន្ធិសញ្ញានេះ។

ធ្វើនៅ ....ភ្នំពេញ......... ថ្ងៃទី ២៦..... ខែ កញ្ញា.. ឆ្នាំ ២០១៩..... ជាពីរច្បាប់ ដោយសំណៅនីមួយៗត្រូវបានធ្វើឡើងជាភាសាខ្មែរ ភាសារុស្ស៊ី និងភាសាអង់គ្លេស និងមានតម្លៃប្រើប្រាស់ស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

សម្រាប់ព្រះរាជាណាចក្រកម្ពុជា

សម្រាប់សហព័ន្ធរុស្ស៊ី

TREATY

ON

MUTUAL LEGAL ASSISTANCE IN CRIMINAL MATTERS

BETWEEN

THE KINDOM OF CAMBODIA

AND

THE RUSSIAN FEDERATION

TREATY

ON

MUTUAL LEGAL ASSISTANCE IN CRIMINAL MATTERS

BETWEEN

THE KINGDOM OF CAMBODIA

AND

THE RUSSIAN FEDERATION

The Kingdom of Cambodia and the Russian Federation hereinafter referred to as the Parties,

recognizing the existing friendly relations and cooperation between the Parties;

desiring to strengthen the legal foundation of providing mutual legal assistance in criminal matters;

desiring to improve the effectiveness of activity of both Parties in combating crime, including crimes relating to terrorism, through cooperation and mutual legal assistance in criminal matters;

acting in accordance with their laws and also respecting generally recognized principles of international law, in particular principles of sovereign equality, territorial integrity and non-interference with internal affairs,

have agreed as follows:

Article 1
Scope of Legal Assistance

Mutual legal assistance in criminal matters (hereinafter referred to as "legal assistance") shall include

1) service of documents;
2) obtaining testimony and statements of persons;
3) location and identification of persons;

4) location and identification of objects, as well as proceeds and instrumentalities of crimes, including the ones for the purposes of terrorism;

5) notification to witnesses, victims and experts of a request for their voluntary appearance before the competent authorities of the Requesting Party;

6) temporary transfer of persons in custody or serving a sentence in the form of imprisonment to testify or to assist in investigations under this Treaty;

7) executing measures related to assets;

8) transfer of documents, objects and other evidence;

9) granting permission to the representatives of the competent authorities of the Requesting Party to be present at the execution of the request;

10) search and seizure;

11) granting any other types of legal assistance consistent with the purposes of this Treaty, provided it is not in contravention to the law of the Requested Party.

Article 2
Obligation to Grant Legal Assistance

1. The Parties shall, in accordance with this Treaty, grant each other comprehensive legal assistance

2. Legal assistance is provided in accordance with this Treaty if the offence, in connection with which the request was issued, is criminally punishable according to the law of both Parties. The Requested Party may upon its own consideration grant legal assistance also in case the offence, in connection with which the request was received, is not criminally punishable under its legislation.

3. The purpose of this Treaty is exclusively granting legal assistance by one Party to the other Party. Provisions of this Treaty do not lead to the creation of rights for any natural persons or legal entities to receive or exclude evidence or prevent execution of the request for legal assistance.

4. Legal assistance for the purpose of this Treaty shall be any assistance given by the Requested Party in respect of investigations or proceedings in the jurisdiction of the Requesting Party in a criminal matter, irrespective of whether the assistance is sought or to be provided by a court or other competent authority.

5. Legal assistance shall also be granted in connection to investigations, or proceedings relating to criminal offences concerning taxation, customs and similar duties, international transfer of financial assets, including the ones which to the Requesting Party appear to be furthering organized criminal activity and crimes

punishable in accordance with multilateral international treaties, where both Parties are participants, in the sphere of combating terrorism.

6. This Treaty does not grant to the competent authorities of one Party the rights to execute in the territory of other Party, powers, which fall exclusively within the competence of the other Party.

7. This Treaty shall apply to requests for legal assistance, presented after the entry into force of this Treaty even if the corresponding act or omission took place before this date.

Article 3
Central Authorities

1. In order to provide for the appropriate cooperation of the Parties in the framework of this Treaty Central Authorities for the Parties shall be appointed.

For the Kingdom of Cambodia, the Central Authority shall be:

The Ministry of Justice.

For the Russian Federation the Central Authorities shall be:

The Ministry of Justice of the Russian Federation for purposes connected with the proceedings of the courts of the Russian Federation;

The General Prosecutor's Office of the Russian Federation for all other purposes of granting legal assistance.

The Parties shall immediately notify each other through the diplomatic channels of any changes of their Central Authorities and spheres of their competence.

2. The Central Authorities of the Parties shall directly transmit and receive all requests for legal assistance provided for in this Treaty and responses to them.

3. The Central Authority will execute requests for legal assistance directly or where necessary direct it for execution to a competent authority-and facilitate prompt and appropriate execution of the request by such competent authority.

Article 4
Form and Contents of the Request

1. A request for legal assistance shall be made in writing. The Requested Party shall immediately receive the request for the execution upon its delivering by telex, facsimile, electronic mail or other such type of communication and the original of the request shall be submitted promptly thereafter by the Requesting Party. The Requested

Party shall inform the Requesting Party of the results of the execution of the request only with the condition that it receives the original of the request.

2. Request for legal assistance shall contain:

a) the name of the competent authority requesting legal assistance;

b) the purpose of the request and description of the requested legal assistance;

c) a description of the offence in connection with which the investigation or the proceedings are conducted, legal qualification, applicable statutory provisions, the text of the relevant law in terms of which the offence is criminally punishable, and also if necessary the nature and extent of the loss or damage caused as a result of this offence;

d) reasons for use and a description of any particular procedures that the Requesting Party wishes to be followed in execution of the request;

e) data identifying persons who are the subjects of the investigation or the proceedings;

f) any time limit within which compliance with the request is desired by the Requesting Party;

g) full names (in particular given name, surname or patronymic/middle name, if any), and addresses and also if possible telephone numbers of the persons who are to be notified and their connection to the investigation or proceedings in progress;

h) indication of the location and description of the place, where inspection and search is required, and of the objects to be seized;

i) questions to be asked in order to gather evidence from witnesses and other persons;

j) in case of an indication that the presence of representatives of the competent authorities of the Requesting Party is desired, their full names and official designations as well as grounds for their presence;

k) the need, if any, for confidentiality of the fact that the request was received, of its contents and/or of any action undertaken in connection with the request;

l) any other information that might be useful to the Requested Party in order to execute the request.

3. If the Requested Party considers that the information contained in the request is insufficient for its execution, that Party may request additional information.

4. Request for legal assistance may include:

a) in the case of request for the taking of evidence, search and seizure, or the location, restraint or forfeiture of proceeds of crime, a statement indicating the basis for belief that evidence or proceeds may be found in the Requested Party;

b) in the case of request to take evidence, the information whether this evidence shall be sworn, affirmed or taken otherwise as stipulated for by the law of the Requesting Party;

c) in the case of request for lending of exhibits, information of the current location of the exhibits in Requested Party and an indication of persons who will have custody of the exhibits in the Requesting Party, the place to which the exhibit is to be transmitted, any analysis to be conducted and the date by which the exhibit shall be returned;

d) in case of request for taking restrictive measures for further forfeiture of proceeds or instrumentalities of crimes:

(i) detailed description of the assets, proceeds or instrumentalities of crime including their location;

(ii) information giving grounds to believe that the assets are proceeds or instrumentalities of crimes;

(iii) description of evidence, which shall be the subject of examination in judicial proceedings in the Requesting Party.

Article 5
Languages

Request for legal assistance, its supporting documents and additional information forwarded in accordance with this Treaty shall be accompanied by translation into the language of the Requested Party, or into English. The same procedure shall be applied to the documents and information forwarded in response to such request.

Article 6
Refusal or Postponement of Requests

1. Legal assistance may be refused if:

a) the execution of the request would impair the sovereignty, security, public order or other essential interests of the Requested Party;

b) the execution of the request is contrary to the law of the Requested Party or does not comply with the provisions of this Treaty;

c) the request relates to the offence for which the person accused of criminal offence in the Requesting Party was convicted or acquitted in the Requested Party in connection with the same offence;

d) the request relates to a crime under military law that is not a crime under general criminal law;

e) the Requested Party has substantial reasons to believe that the request was submitted in order to prosecute the person on grounds of race, gender, faith, citizenship, ethnic origin, affiliation with certain social group or political convictions, or the position of that person may be prejudiced because of any of these causes.

2. Bank secrecy or confidentiality of taxation may not be invoked for the refusal to grant legal assistance.

3. Legal assistance may be postponed or refused by the Requested Party if execution of the request would interfere with an ongoing investigation or proceedings in connection with a criminal matter in the Requested Party.

4. Before making a decision to postpone or refuse the execution of the request the Requested Party shall consider whether legal assistance may be granted subject to such conditions, as it deems necessary. If the Requesting Party accepts legal assistance subject to these conditions, it is obliged to comply with them.

5. The Requested Party shall promptly inform the Requesting Party of its decision not to comply in whole or in part with a request for legal assistance, or to postpone execution, and shall give reasons for that decision.

Article 7
Validity of the Documents

1. Documents transmitted pursuant to this Treaty and attested to by the seal of competent or Central Authority of the transmitting Party are admissible in evidence without further authentication.

At the request of the Requesting Party, the documents transmitted within the framework of this Treaty may be certified in any other form, as indicated in the request provided that is not contrary to the legislation of the Requested Party.

2. For the purposes of this Treaty the documents, which are recognized as official in the territory of one Party shall subject to provisions of this Article be recognized as such in the territory of the other Party.

Article 8
Confidentiality and the Limitations of use of Information

1. The Requested Party upon request of the Central Authority of the Requesting Party shall provide in accordance with its legislation for the confidentiality

of the fact of the receipt of the request for legal assistance, of its contents or any action taken pursuant to the request, excluding the cases when the breach of confidentiality of the request is necessary for its execution.

If the execution of the request makes it necessary to remove this limitation, the Requested Party shall in writing seek the permission of the Requesting Party, without which the request will not be executed.

2. The Requesting Party shall not use the information or evidence obtained under this Treaty without the permission of the Requested Party for purposes other than those indicated in the request for legal assistance.

3. In cases where the Requesting Party needs to disclose and use fully or in part the information or evidence for purposes other than those stated in the request, it shall seek the consent of the Requested Party, which may either agree or refuse, fully or partially, such permission, as the case may be.

Article 9
Execution of Requests

1. Requests for legal assistance shall be executed in accordance with the laws of the Requested Party and the provision of this Treaty.

At the request of the Requesting Party, the Requested Party shall grant legal assistance in form and in accordance with any special procedure indicated in the request, insofar as it is not inconsistent with the laws of the Requested Party.

2. If the Requesting Party seeks the presence of the representatives of its competent authorities during the execution of a request, the Requested Party will inform the Requesting Party about its decision. In case of a positive decision, the Requesting Party will be informed beforehand, about the time and the place of the execution of the request.

3. The Central Authority of the Requested Party will transmit the information and the evidence received consequent to the request to the Central Authority of the Requesting Party within a reasonable time.

4. If it is not possible to execute the request in full or in part, the Central Authority of the Requested Party will immediately inform the Central Authority of the Requesting Party of such inability and also the reasons therefore.

Article 10
Service of Documents

1. In accordance with the request for legal assistance the Central Authority of the Requested Party shall immediately serve or arrange through the competent authority the service of any documents.

2. The Requesting Party shall transmit a request for the service of a document pertaining to a response or appearance in the territory of the Requesting Party within a reasonable time, before the scheduled response or appearance, normally not later than 60 days before the date of appearance.

3. The Central Authority of the Requested Party shall forward a proof of service in accordance with its laws and procedure. Such proof of service shall indicate the date, the signature of the addressee and/or the statement of the competent authority of the Requested Party, if any, in which the fact of service, the date and the manner of service are confirmed.

Article 11
Taking of Evidence

1. Where a request is made that evidence be taken for the purpose of investigation or proceeding in relation to a criminal matter in the jurisdiction of the Requesting Party, the Requested Party shall arrange to have such evidence taken.

2. For the purposes of this Treaty giving or taking of evidence shall include testimony of the witnesses, victims and other persons connected to the criminal proceedings, conclusions of experts, the production of documents, articles or records.

3. The representatives of the competent authorities of the Requesting Party that are present at the execution of the request shall be allowed to formulate questions that may be put to the corresponding person through the representative of the competent authority of the Requested Party.

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមុខតំណែងឯកឧត្តម **សុខ សុខារ** ជាអនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

១៧.២០១២.១៤១០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

យើង

នស/រកត/១២២០/ ១៣៧៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមុខតំណែងឯកឧត្តម **សុខ សូភាន** ជារដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ចារស. ២០១២. ១៤៧៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១២២០/ ១៣៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងឯកឧត្តម **អ៊ិន វី** ពីទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក**។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]. ២០១៤.១៤១៤

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១២២០/១៣៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ :

១-វរសេនីយ៍ឯក **ទេព ចន្ទី** អត្តលេខ ០២៥២៧៤
២-វរសេនីយ៍ឯក **កុសល សុវណ្ណមរកត** អត្តលេខ ២៣១៦៩២
៣-វរសេនីយ៍ឯក **ហ៊ុល វណ្ណី** អត្តលេខ ២២៤៧៦០
៤-វរសេនីយ៍ឯក **ស៊ឹម ចំរ៉ុង** អត្តលេខ ២០៩៤៩១
៥-វរសេនីយ៍ឯក **ម៉ី វណ្ណដា** អត្តលេខ ០៧៧៩៧០
៦-វរសេនីយ៍ឯក **លន បរិសុទ្ធ** អត្តលេខ ០២៦១៣១
៧-វរសេនីយ៍ឯក **ឌិល សុវណ្ណារ៉ា** អត្តលេខ ០៦២០៥១

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៨-វរសេនីយ៍ឯក **សរ ស្រី** អត្តលេខ ០៤៦៦៨៨

៩-វរសេនីយ៍ឯក **ឡើន ចណ្ណារ៉ា** អត្តលេខ ០៥៦៣១៣

១០-វរសេនីយ៍ឯក **ផន ឃិនយុរ៉ា** អត្តលេខ ០៦៧៩០១

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

នស/រកត/១២២០/១៤១៣

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១២២០/១៣៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ជូន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោក	ផាក	ហាន់ហ្គីល	PARK HAN-GILL
២-លោក	យូន	យ៉ុងស៊ុង	YOON YOUNG SUNG
៣-លោក	យូ	ហ្យុងចាង	YU HYUNG CHANG

៧៣៥ . ២០១៤ . ១៤១៤

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះមានគោលបំណងធានាការគ្រប់គ្រង និងការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានប្រកបដោយតម្លាភាព អព្យាក្រឹត្យ និងមិនរើសអើង ដោយកំណត់អំពី៖

- ការគ្រប់គ្រង ការប្រមូល និងការចាត់ចែងមូលនិធិការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

មាត្រា២ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១. **គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍** សំដៅដល់ស្ថាប័នទទួលបន្ទុកផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលទទួលស្គាល់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

២. **ចំណូលដុល** សំដៅដល់ប្រាក់ចំណូលទាំងអស់របស់ប្រតិបត្តិករទូរគមនាគមន៍ ដែលបានមកពីប្រតិបត្តិការទូរគមនាគមន៍ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ ដោយមិនទាន់កាត់កងចំណាយណាទាំងអស់ លើកលែងតែចំណូលពីការលក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍។

៣. **មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តទៅសរសេរកាត់ថា "**មូលនិធិ ស.អ**"។

ជំពូកទី២
គណៈកម្មាធិការគ្រប់គ្រងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

មាត្រា៤ .-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	ប្រធាន
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ២រូប	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប	អនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប	សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប	សមាជិក
- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប	សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា៥ .-

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងចាត់ចែងមូលនិធិ ស.អ
- លើកកម្ពស់ និងជំរុញការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពិនិត្យ និងសម្រេចលើកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើផែនការនិងយន្តការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- ពិនិត្យ និងសម្រេចលើយន្តការទូទាត់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជូនរាជរដ្ឋាភិបាល
- ផ្ដល់យោបល់ជូនរាជរដ្ឋាភិបាលអំពីវិភាគទានពីប្រតិបត្តិករទូរគមនាគមន៍ ដែលត្រូវចូលរួមក្នុងមូលនិធិ ស.អ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋ ឬឯកជន ឬដៃគូអភិវឌ្ឍន៍
- ពិនិត្យ និងសម្រេចលើការផ្ដល់ ការបន្ត ការផ្អាក ការផ្ទេរ ឬការបញ្ឈប់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើថវិកាសម្រាប់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើថវិកាប្រចាំឆ្នាំរបស់មូលនិធិ ស.អ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិ ស.អ ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា៦ .-

អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ជំនួសបាន។

មាត្រា៧ .-

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចមានអ្នកជំនាញការជាតិ ឬអន្តរជាតិមួយចំនួនដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស។

មាត្រា៨ .-

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា៩ .-

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានអគ្គនាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាសេនាធិការផ្នែកបច្ចេកទេស និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

តួនាទី និងភារកិច្ចរបស់សេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា១០ .-

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានកញ្ចប់ថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន ដែលត្រូវដកចេញពីមូលនិធិ ស.អ ប្រចាំឆ្នាំយ៉ាងច្រើន ១០ (ដប់) ភាគរយ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមសំណើរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីដែលបម្រើការងារក្នុងសេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី៣
មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ផ្នែកទី១
ការប្រមូលនិងការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

មាត្រា១១ .-

ប្រភពធនធាននៃមូលនិធិ ស.អ រួមមាន៖

- វិភាគទានប្រចាំឆ្នាំចំនួន ១ (មួយ) ភាគរយ នៃចំណូលដុលរបស់ប្រតិបត្តិករទូរគមនាគមន៍ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍
- ធនធានដែលរដ្ឋ ឬក្រសួង ស្ថាប័ននានាផ្តល់ឱ្យមូលនិធិ ស.អ សម្រាប់អនុវត្តគម្រោងរួមគ្នា
- ហិរញ្ញប្បទាន អំណោយ ថវិកាជំនួយ សម្ភារៈបរិក្ខារ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- ធនធានដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត។

ធនធាននៃមូលនិធិ ស.អ ត្រូវរក្សាទុកក្នុងគណនីរបស់មូលនិធិ ស.អ នៅធនាគារពាណិជ្ជណាមួយ ដោយមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១២ .-

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានចំនួន ១ (មួយ) ភាគរយ នៃចំណូលដុលឆ្នាំចាស់ទៅក្នុងគណនីមូលនិធិ ស.អ យ៉ាងយូរបំផុត ៩០ (កៅសិប) ថ្ងៃ ក្រោយការិយបរិច្ឆេទនៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច មកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ក្នុងករណីមានលម្អៀងខ្វះនៃការគណនាទឹកប្រាក់បង់វិភាគទាន ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់បង្គ្រប់ក្នុងឆ្នាំដែលត្រូវបង់វិភាគទាន។ ក្នុងករណីមានលម្អៀងលើសនៃការគណនា ទឹកប្រាក់បង់វិភាគទានត្រូវរក្សាទុកក្នុងគណនីរបស់មូលនិធិ ស.អ សម្រាប់បង់នៅឆ្នាំបន្ទាប់។

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍បង់វិភាគទានយឺតយ៉ាវលើសពីរយៈពេលដូចបានកំណត់ខាងលើ ប្រតិបត្តិករទូរគមនាគមន៍នោះត្រូវរងពិន័យជាប្រាក់ចំនួន ២ (ពីរ) ភាគរយ ក្នុងមួយខែ ដោយបូកយោងជា

បន្តបន្ទាប់តាមចំនួនខែដែលជំពាក់ តាមរូបមន្ត $X(1+r)^n$ ដែល X ជាបំណុលដើម r ជាអត្រាពិន័យក្នុងមួយខែ និង n ជាចំនួនខែ។

មាត្រា១៣ .-

កម្មវត្ថុនៃការប្រើប្រាស់មូលនិធិ ស.អ មានជាអាទិ៍ ដូចខាងក្រោម៖

ក. កសាងហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលនវានុវត្តន៍ មន្ទីរពិសោធន៍ ឬបន្ទប់ពិសោធន៍បម្រើឱ្យការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍ លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ខ. អប់រំ និងបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ. សិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឃ.គាំទ្រដល់ការបង្កើតអាជីវកម្មនិងសេវាកម្មថ្មីៗលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ង. ផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ច. បង្កើតព្រឹត្តិការណ៍ និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងធ្វើឱ្យកាន់តែប្រសើរឡើង នូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឆ. បង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យា និងភាពជាសហគ្រិនធ្វើមលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ជ. ចំណាយរដ្ឋបាលរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ និង

ឈ.កម្មវត្ថុផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

មាត្រា១៤ .-

ប្រតិបត្តិករទូរគមនាគមន៍ដែលបានបង់វិភាគទានមូលនិធិ ស.អ មានសិទ្ធិស្នើសុំយ៉ាងច្រើនត្រឹម ២០ (ម្ភៃ) ភាគរយនៃមូលនិធិដែលខ្លួនបានបង់ ចំពោះគម្រោងជាអាទិ៍៖

- អប់រំ និងបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បង្កើតព្រឹត្តិការណ៍ និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងធ្វើឱ្យកាន់តែប្រសើរឡើង នូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យា និងភាពជាសហគ្រិនធ្វើមលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និង
- កម្មវត្ថុផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានសិទ្ធិចាត់ចែងមូលនិធិ ស.អ ដែលនៅសេសសល់ក្នុងគោលដៅ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ហើយផលដែលកើតចេញពីការប្រើប្រាស់មូលនិធិនេះ

ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រសួង ស្ថាប័ន ឬនីតិបុគ្គលដទៃទៀត អាចគ្រប់គ្រង និងចាត់ចែងផលពីគម្រោងនៃមូលនិធិ ស.អ បាន តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់មូលនិធិ ស.អ ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

មាត្រា១៥ .-

កញ្ចប់ថវិការបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវប្រើប្រាស់សម្រាប់មុខសញ្ញាចំណាយដូចខាងក្រោម៖

- ដំណើរការ និងការបំពេញភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ សេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ
- ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន ទីប្រឹក្សាបច្ចេកទេស មន្ត្រីរាជការ និងបុគ្គលិកនៃសេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ការទិញ ការជួល ការជួសជុល ឬការថែទាំយានជំនិះ សង្ហារិម សម្ភារៈការិយាល័យ
- ចំណាយលើប្រេងឥន្ធនៈ ប្រេងរំអិល
- ចំណាយជាក់ស្តែងផ្សេងៗទៀតតាមការចាំបាច់របស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ផ្នែកទី២
លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំ ការផ្តល់ និងការទូទាត់ គម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

មាត្រា១៦ .-

បុគ្គលដែលមានសិទ្ធិស្នើសុំមូលនិធិ ស.អ មានដូចខាងក្រោម៖

- ប្រតិបត្តិករទូរគមនាគមន៍ដែលបានបំពេញប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ និងបានអនុវត្តកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន
- គ្រឹះស្ថានសាធារណៈ ដែលផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បុគ្គលផ្សេងទៀតដែលមានគុណវុឌ្ឍិឆ្លើយតបទៅនឹងកម្មវត្ថុណាមួយ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ។

មាត្រា១៧ .-

បុគ្គលដែលអាចទទួលបានមូលនិធិ ស.អ ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- បានអនុវត្តកាតព្វកិច្ចបង់ភាគទានចូលមូលនិធិ ស.អ ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ចំពោះបុគ្គលស្នើសុំជាប្រតិបត្តិករទូរគមនាគមន៍

ថ្វ

- ពុំមានជាប់បំណុលដោយការខកខានបង់វិភាគទានចូលមូលនិធិ ស.អ ឬខកខានបង់ចំណូលពីប្រតិបត្តិការផ្សេងៗដែលកំណត់ដោយច្បាប់ស្តីពីទូរគមនាគមន៍ ចំពោះបុគ្គលស្នើសុំជាប្រតិបត្តិករទូរគមនាគមន៍
- មានសក្តានុពលភាពផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងមានឆន្ទៈក្នុងការសម្រេចនូវគម្រោងកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

មាត្រា១៨ .-

បុគ្គលដែលស្នើសុំមូលនិធិ ស.អ ត្រូវដាក់ពាក្យស្នើសុំទៅគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ យ៉ាងយូរត្រឹមដំណាច់ខែមករានៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីពិនិត្យ និងសម្រេច។

ក្នុងករណីដែលគម្រោងត្រូវបានជ្រើសរើស បុគ្គលដែលស្នើសុំមូលនិធិ ស.អ ត្រូវធ្វើការសិក្សា និងផ្តល់របាយការណ៍សមិទ្ធិលទ្ធភាពជូនគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដោយភ្ជាប់មកជាមួយនូវឯកសារគម្រោងបច្ចេកទេស និងហិរញ្ញវត្ថុ និងផែនការសកម្មភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិត នៃការសម្រេច ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

បុគ្គលដែលស្នើសុំមូលនិធិ ស.អ អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

រាល់គម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលត្រូវបានសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវផ្សព្វផ្សាយជាសាធារណៈ។

មាត្រា១៩ .-

ការផ្តល់ថវិកាដល់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវធ្វើឡើងតាមរយៈការផ្ទេរវាងគណនីធនាគារ ក្រោយពេលដែលគម្រោងទទួលបានការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

បែបបទ និងនីតិវិធីនៃការផ្តល់ថវិកានេះ អាចត្រូវបានកំណត់បន្ថែមដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ផ្នែកទី៣
ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ
ការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

មាត្រា២០ .-

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជូនគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

៤

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវបង្កភាពងាយស្រួល និងសហការជាមួយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ក្នុងការចុះត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងឆ្លើយតបទៅនឹងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង។

ក្នុងករណីដែលគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានណាមួយមិនដំណើរការ ឬដំណើរការពុំស្របតាមផែនការសកម្មភាព គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចចាត់វិធានការបន្ទាន់ ដើម្បីផ្អាក ឬបញ្ឈប់ការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងដាក់ទណ្ឌកម្មដូចមានចែងជំពូកទី៤ នៃអនុក្រឹត្យនេះ។

ជំពូកទី៤
ទណ្ឌកម្ម

មាត្រា២១ .-

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍មិនបង់វិភាគទានកាតព្វកិច្ចនៃមូលនិធិ ស.អ គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចស្នើសុំទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក. បង្កកការនាំចេញ និង/ឬ ការនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ. បង្កកគណនីរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

គ. ដាក់កំហិតលើអាជ្ញាបណ្ណ

ឃ. ព្យួរអាជ្ញាបណ្ណ

ង. ព្យួរបណ្ដោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់ របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ

ច. ជ្រើសរើស និងផ្ដល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ច ដើម្បីពិនិត្យសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ

ឆ. ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

មាត្រា២២ .-

ដោយពុំទាន់រាប់បញ្ចូលទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងទណ្ឌកម្មព្រហ្មទណ្ឌ ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ដែលមិនអនុវត្តតាមគម្រោង អនុវត្តគម្រោងមិនបានត្រឹមត្រូវ ប្រើប្រាស់មូលនិធិមិនសមស្រប តាមរយៈការលួចកិបកេង ក្លែងបន្លំ ឬប្រើប្រាស់ខុសគោលដៅ ជាអាទិ៍ ត្រូវបង្វិលទឹកប្រាក់ដែលបានទទួល បូករួមទាំងការប្រាក់ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃ

ដែលរកឃើញថាបានប្រព្រឹត្តល្មើស មកគណនីរបស់មូលនិធិ ស.អ វិញ។ ការបង្វិលប្រាក់ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

មាត្រា២៣ .-

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ មិនអនុវត្តតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដូចមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ គណៈកម្មាធិការអាចសម្រេចចាត់វិធានការលើប្រតិបត្តិករទូរគមនាគមន៍នោះតាមជម្រើសណាមួយ ដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

ក្នុងករណីបុគ្គលដែលទទួលបានមូលនិធិ ស.អ មិនអនុវត្តតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដូចមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ គណៈកម្មាធិការអាចសម្រេចចាត់វិធានការដូចខាងក្រោម៖

- មិនអនុញ្ញាតឱ្យចូលរួមស្នើសុំមូលនិធិ ស.អ នាពេលអនាគត
- ផ្សព្វផ្សាយជាសាធារណៈតាមបណ្ដាញសារព័ត៌មាន ឬគេហទំព័រ
- ប្ដឹងទៅតុលាការមានសមត្ថកិច្ច។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា២៤ .-

លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលពាក់ព័ន្ធនឹងការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា២៥ .-

អនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា៥ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា២៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ជា វ៉ាន់ដេត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៩៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១១៨៣៥/១២៧១ កសក.គបហ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សម្រេច

មាត្រា១.-

ត្រូវបានធ្វើអនុបយោគផ្ទៃដី១កន្លែងទំហំ ១ ២០០ (មួយពាន់ពីររយ) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រដែត ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដូចបង្ហាញក្នុងផែនទីដែលមានប្លង់បង្ហាញទីតាំងដី និងអគារភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២.-

ផ្ទៃដីដែលបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ស្របតាមនីតិវិធីប្រទានកម្មជាធរមាន។

មាត្រា៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ១២ ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ប្លង់បង្ហាញទីតាំងដី និងអគារ

ដែលស្នើសុំកាត់ចេញពីផ្ទៃដីការិយាល័យកសិកម្ម ស្រុកស្វាយទាប ខេត្តស្វាយរៀង

ស្ថិតនៅភូមិត្រដែត ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង



និយាមការចំណុចព្រំដី		
ID	X	Y
1	597377.461	1221492.251
2	597391.541	1221503.36
3	597362.947	1221556.341
4	597349.892	1221580.531
5	597323.937	1221569.088
6	597339.607	1221544.44
7	597349.897	1221537.574
8	597344.081	1221546.721

-វាស់វែងដោយប្រើប្រាស់ម៉ាស៊ីនទំនើប ឌី ជី ភីអេស T300 Plus

........ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០

មន្ត្រីអង្កេតវាស់វែង

(ហត្ថលេខា)

ចំរើន.រតនា

កំណត់សំគាល់

- ⊙ បង្គោលព្រំដី
- ━ ព្រំដី
- ☐ ដីរបស់ការិយាល័យកសិកម្មស្រុកទំហំ ២៤៨៤ ម៉ែត្រការ៉េ
- ▨ ដីប្រជាពលរដ្ឋស្នើសុំទំហំ ១២០០ ម៉ែត្រការ៉េ
- ▦ ដីនៅសល់ទំហំ ៧៦៥ម៉ែត្រការ៉េ

បានឃើញ និងឯកភាព

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់

និងភូមិបាលស្រុកកំពង់រោទិ៍

............ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០

(ហត្ថលេខា)

សេក-សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០១៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនាឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា១. បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៩០រូប នៃក្រសួងយុត្តិធម៌ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

១-លោកស្រី	សុផុន	សុមានីកា	ក្រឡាបញ្ជីតុលាការកំពូល
២-លោក	សៅ	ផល្លី	ក្រឡាបញ្ជីសាលាឧទ្ធរណ៍បាត់ដំបូង
៣-លោក	អៃ	សារ៉ែន	ក្រឡាបញ្ជីសាលាឧទ្ធរណ៍ត្បូងឃ្មុំ
៤-លោក	សួស	រិទ្ធី	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តបាត់ដំបង
៥-លោក	សំរិទ្ធ	សុធារិទ្ធិ	ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត
៦-លោកស្រី	សៃ	អូន	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកំពត
៧-លោកស្រី	ឯក	តារា	ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
៨-លោក	ប៉ែន	ភរិម្យ	ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
៩-លោក	ប៉ោ	សុកនី	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

ស៊ីន

១០-លោក ហៀវ សុគន្ធ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
១១-លោក ង៉ែត កុសមគ្គា ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង
១២-លោក យ៉េង ពន្លក ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង
១៣-លោក ជឹម សូយ៉េត ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តព្រៃវែង
១៤-លោក ទូច សុផល ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់
១៥លោកស្រី ច័ន្ទ និម្មល្ល ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី
១៦-លោក វ៉ាយ វណ្ណឡា ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តរតនគិរី

ខ-មេដាយ**ធ្វារកំការងារ**

១-លោកស្រី ប៉េស វីណា ក្រឡាបញ្ជីសាលាឧទ្ធរណ៍ភ្នំពេញ
២-លោកស្រី ថាវ សុចាន់មុនី ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកំពង់ធំ
៣-លោក ហាង់ យ៉េង ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកណ្តាល
៤-លោក កន សុវណ្ណឫទ្ធិ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៥-លោក ហាក់ ជ្រុយ ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ
៦-លោកស្រី អ៊ុក ធីម ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ
៧-លោក នួន ចាន់រស្មី ក្រឡាបញ្ជីអយ្យការអមសាលដំបូងខេត្តតាកែវ

គ-មេដាយ**សំរឹទ្ធការងារ**

១-លោក ស ចំរើន ក្រឡាបញ្ជីសាលាឧទ្ធរណ៍ភ្នំពេញ
២-លោក ជួន វុទ្ធី ក្រឡាបញ្ជីសាលាឧទ្ធរណ៍ភ្នំពេញ
៣-លោកស្រី ឡាច សុភាព ក្រឡាបញ្ជីមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ
៤-លោក មាន ថាវរី ក្រឡាបញ្ជីសាលាឧទ្ធរណ៍ព្រះសីហនុ
៥-លោក សុន រតនា ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ
៦-លោក សំ វាសនា ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ
៧-លោក កែវ សាវី ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តបន្ទាយមាជ័យ
៨-លោក នៅ ច័ន្ទថា ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង
៩-លោក ម៉ៅ សាវឿត ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង
១០-លោក ទ្រី ហាន់ ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម
១១-លោក សុខ គឹមស៊ិន ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម
១២-លោក ថាន់ បូរ៉ាន់ ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកំពង់ចាម
១៣-លោកស្រី ឯម ស្រីធា ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង
១៤-លោក ដាក សម្ផស្ស ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង
១៥-លោក ជា សុសន ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ
១៦-លោក ហ្វូត ថាវរិត ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ
១៧-លោក សេង វាសនា ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

ហ៊

១៨-លោក	អែម	សុផារិទ្ធ	ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ
១៩-លោក	អ៊ុំ	ស្រី	ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
២០-លោកស្រី	មាស	សុខនី	ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
២១-លោក	អ៊ិន	ស៊ឹងទ្រី	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តកោះកុង
២២-លោក	ហួត	ចន្ទ្រា	ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ
២៣-លោក	សយ	យ៉ាន់សន្តិវង្សី	ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ
២៤-លោក	នៅ	ចំណាប់	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តក្រចេះ
២៥-លោក	លី	ចន	ក្រឡាបញ្ជីសាលាដំបូងខេត្តមណ្ឌលគិរី
២៦-លោក	បូ	បុណ្ណវឌ្ឍន៍	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
២៧-លោក	ឡាយ	ណារិទ្ធ	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
២៨-លោក	ហ៊ឹម	សិរីវុឌ្ឍ	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
២៩-លោក	ខូ	គឹមឈាង	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣០-លោកស្រី	ចាន់	បញ្ញាវ័ត្ត	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣១-លោក	ផា	និមល	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣២-លោក	លឹម	ប៉េងអៀង	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៣-លោកស្រី	ប្រង់	ពេជ្រមាលា	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៤-លោក	សុខ	ទី	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៥-លោក	ផល	សុភ័ក្ត្រ	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៦-លោកស្រី	អ៊ិត	ឡុងឌី	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៧-លោកស្រី	ឃុត	សុនិតា	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៨-លោកស្រី	អ៊ូ	គាវ៉ាន់	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៣៩-លោក	សឿង	រតនា	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
៤០-លោកស្រី	ហាក់	ស្រីពៅ	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
៤១-លោក	ផន	សុធារិទ្ធ	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
៤២-លោក	កេង	វិរៈ	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
៤៣-លោក	ចេង	សុផាន	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
៤៤-លោក	ថន	ផល	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
៤៥-លោក	ហែម	ភក្តី	ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ
៤៦-លោក	កែវ	បុលសម្បត្តិ	ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ
៤៧-លោក	ហេង	សេងហួត	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តព្រះវិហារ
៤៨-លោក	ទិត	សុខខឿន	ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់
៤៩-លោកស្រី	អ៊ុក	ចន្ថា	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់
៥០-លោកស្រី	ឈុន	លក្ខិណា	ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប
៥១-លោក	យេង	ដា	ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប
៥២-លោក	កែវ	សំបាន	ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

៥៣-លោក	ហួយ	ឆវណ្ណ	ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប
៥៤-លោកស្រី	សួន	ច័ន្ទមិនា	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តសៀមរាប
៥៥-លោក	ទៀង	សំណាង	ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ
៥៦-លោក	វិត	បញ្ញា	ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ
៥៧-លោកស្រី	លុយ	សុវត្ថិ	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ
៥៨-លោកស្រី	មុំ	សុភ័ក្រ	ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង
៥៩-លោក	ឧន	ដារ៉ូ	ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង
៦០-លោក	ធឿន	ប៊ុននី	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង
៦១-លោក	ស៊ិន	ប៊ុនណាភ័ត់	ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង
៦២-លោក	ឌី	ម៉េងនាង	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តស្វាយរៀង
៦៣-លោក	ឯក	ថាវី	ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ
៦៤-លោក	ឃួន	សំបូរ	ក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន
៦៥-លោក	សន	វុទ្ធី	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តប៉ៃលិន
៦៦-លោក	ម៉ុញ	សារ៉េន	ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ
៦៧-លោក	វេ	សុភ័ក្ត	ក្រឡាបញ្ជីអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០១៦ អនក្រ.តត

អនុក្រឹត្យ

ស្ដីពី

ការផ្ទេរក្របខណ្ឌ និងតែងតាំងឋានន្តរសក្ដិមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ផ្ទេរក្របខណ្ឌលោក **ខិន ទុទ្ធី** ពីឋានន្តរសក្ដិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ១ នៃក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ មកឋានន្តរសក្ដិ **វរសេនីយ៍ឯក** អត្តលេខ ៩០៧៥១ នាយនគរបាលជាន់ខ្ពស់ នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហ.១១កើត ខែមិគសិរ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ✓

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០១៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ៖ ផ្ទេរ និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **អ៊ុក សំណាង** អត្តលេខ ១២១៥៨ ជាប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ។

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០១៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងផ្លាស់ប្តូរមុខតំណែង នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : តែងតាំងផ្លាស់ប្តូរមុខតំណែង នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយ៍ឯក	**ម៉ៅ សេង**	អត្តលេខ ០០០៨៣៣	ជា មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២-ឧត្តមសេនីយ៍ទោ	**សោម យ៉ុម**	អត្តលេខ ០០០៨៤៤	ជា ស្នងការ ស្នងការដ្ឋានបច្ចេកទេស បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៣-ឧត្តមសេនីយ៍ទោ	**នោ រុន**	អត្តលេខ ០០៨៦៧៩	ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ
៤-ឧត្តមសេនីយ៍ទោ	**គង់ ណារិន**	អត្តលេខ ០១៤៩៦៥	ជា នាយក មហាវិទ្យាល័យអប់រំចិត្តសាស្ត្រ និង ស្រាវជ្រាវវិទ្យាសាស្ត្រយោធា សាកលវិទ្យាល័យការពារជាតិ

៥-ឧត្តមសេនីយ៍ត្រី **ឡេង ឌីណា** អត្តលេខ ០១៨៥៨៧ ជា មេបញ្ជាការរង យោធភូមិភាគទី២

៦-ឧត្តមសេនីយ៍ត្រី **ជា សុផល** អត្តលេខ ០០៩៨៤៦ ជា មេបញ្ជាការរង យោធភូមិភាគទី២

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែ មិគសិរ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០១៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំង និងផ្តល់ឋានៈលោក **ស្រ៊ុន គុន្ធល** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលយកប្រាក់បំណាច់មុខងារ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ៖ ផ្ទេរ និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **សុគន្ធ ទិសិដ្ឋ** អត្តលេខ ៧៨០១៩ ជាប្រធាននាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃចន្ទ ១៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៥១ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- តាមសំណើរបស់ឯកឧត្តម **ម៉ុល សារឿន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

សម្រេច

មាត្រា១ : តែងតាំងនិងផ្តល់ឋានៈដល់លោកស្រីឧត្តមសេនីយ៍ទោ **ព្រំ សុចិន្តា** ជាជំនួយការឯកឧត្តម **ម៉ុល សារឿន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសលោកវរសេនីយ៍ឯក **សាន ណារិទ្ធ**។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៤៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
